MesOctober-2010 OK.qxd 10/4/2010 4:45 PM Page 1

# អ្នកនាំសារ
## The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី៤ ថ្ងៃទី០១-៣១ ខែតុលា ឆ្នាំ២០១០ លក់តម្លៃ ១០០០រៀល តែប៉ុណ្ណោះ លេខ ៣៨

Formation, Dialogue, Cooperation

## មាតិកា




**យុវជនត្រូវស្គាល់តម្លៃនៃការប្រើប្រាស់អ៊ីនធឺណិត** ទំព័រ ៥



**នាយកបណ្ណាល័យជាតិ: "ការអានគឺជាវប្បធម៌មួយ"** ទំព័រ ៩



**សក្ខីភាពនៃអ្នកម្តាយតេរេសា** ទំព័រ ១៤


# ពិភពលោកមានអ្នកអត់ចេះអក្សរ ៧៥៩ លាននាក់ នៅកម្ពុជា មាន ២លាននាក់



អនក្ខរភាពនៅតែជាបញ្ហាប្រឈមយ៉ាងសំខាន់នៅក្នុងប្រទេសកម្ពុជា។ ក្នុងចំណោមប្រជាជនប្រមាណ ១៤ ០០០ ០០០ នាក់ អ្នកមិនចេះអក្សរមានដល់ទៅជិត ២លាននាក់។ តើប្រទេសជាតិនឹងអាចរីកចម្រើនទៅមុខក្នុងល្បឿនលឿនម្តេចបាន បើមានប្រជាជនលំបាកនឹងឈោងចាប់យកចំណេះដឹង ដោយសារតែការមិនចេះអក្សរនោះ? ទំព័រទី១០_១១


កម្មវិធី **ពន្លកថ្មី** ជាកម្មវិធីវិទ្យុថ្មីមួយរបស់ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក។ កម្មវិធីនេះផ្តោតលើពលកម្មកុមារ និងបញ្ហារការកេងប្រវ័ញ្ចលើកុមារ មានផ្សាយនៅពេល ថ្ងៃច័ន្ទ ម៉ោង ៤-៥ រសៀល នៅវិទ្យុសម្លេងប្រជាធិបតេយ្យ VOD, FM 106.5 MHz។




**អេម៉ានូអែល** សំឡេងពីព្រះសហគមន៍កាតូលិក !

ភ្នំពេញ : FM 102.5 Mhz ម៉ោង២:០០-៣:០០ រាល់រសៀលថ្ងៃសុក្រ
បាត់ដំបង : FM 91.0 Mhz ម៉ោង ៧:៣០-៨:៣០ រាល់យប់ថ្ងៃសៅរ៍
សៀមរាប: FM 102.5 Mhz ១០:០០-១១:០០ រាល់ថ្ងៃសៅរ៍
កំពង់ធំ : FM 88.5 Mhz ម៉ោង ១២:៣០-១:៣០ ថ្ងៃសៅរ៍ថ្ងៃត្រង់
កំពង់ចាម : FM 100.5 Mhz ម៉ោង ៦:៣០-៧:០០ យប់ថ្ងៃអាទិត្យ
ក្រុងព្រះសីហនុ : FM 107.5 Mhz ម៉ោង៥:០០-៦:០០ រសៀលថ្ងៃសៅរ៍
កំពត : FM 93.25 Mhz ម៉ោង ៥:០០-៦:០០ រសៀលថ្ងៃសៅរ៍

# រូបថតប្រចាំខែ



Photo : L. Sovanna

រថក្រោះ និងរថពាសដែកចំនួន ៩៦គ្រឿង ត្រូវបានដឹកមកដល់ប្រទេសកម្ពុជាតាមរយៈ កំពង់ផែអន្តរជាតិក្រុងព្រះសីហនុ កាលពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០។



Photo : S. Philong

គ្រោះមហន្តរាយអគ្គីភ័យមួយបានឆាបឆេះឡើងកាលពីថៃទី២១ កញ្ញា នៅផ្លូវ១៨២ ម្ដុំបុរីកីឡា រាជធានីភ្នំពេញ។ អគ្គីភ័យនេះដែលធ្វើឱ្យខូតខាតទឹកប្រាក់ ២លានដុល្លារ បណ្ដាលមកពីឆេះរថយន្តដឹកសាំងមួយគ្រឿង។



Photo : S. Philong

តន្ត្រីគឺជាសិល្បៈមួយប្រភេទដែលមាតាបិតាគួរយកចិត្តទុកដាក់ និងផ្ដល់ឱ្យកូនៗរបស់ពួកគេ។ បើតាមអ្នកជំនាញ បានអះអាងឱ្យដឹងថា ការចំណាយពេលលេងតន្ត្រីខ្លះនឹងជួយដុះខាតខួរក្បាលមនុស្ស។



Photo : S. Philong

ប្រជាជនកម្ពុជាបានចាប់ផ្ដើមកាន់បិណ្ឌដែលជាពិធីបុណ្យព្រះពុទ្ធសាសនាដ៏សំខាន់មួយកាលពីថៃទី២៤ កញ្ញា។ ពិធីកាន់បិណ្ឌនេះត្រូវធ្វើរហូតដល់ថ្ងៃទី៨ ខែតុលា ដែលជាបុណ្យភ្ជុំបិណ្ឌ។

MesOctober-2010 OK.qxd 10/4/2010 4:45 PM Page 3



# សិទ្ធិទទួលបានការអប់រំ គឺសម្រាប់ពលរដ្ឋទាំងអស់គ្នា



លោកលី សុវណ្ណា ប្រធានការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក (CSC)

ពលរដ្ឋគ្រប់រូបមានសិទ្ធិគ្រប់គ្រាន់ដើម្បីទទួលបាននូវការអប់រំចំពោះចំណេះដឹងផ្សេងៗ ។ រាជរដ្ឋាភិបាលកម្ពុជាបានដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្ររបស់ខ្លួន គឺការអប់រំ ដើម្បីទាំងអស់គ្នាមានន័យ "ពលរដ្ឋកម្ពុជាទាំងអស់មានសិទ្ធិស្មើៗគ្នា ក្នុងការទទួលបាននូវការអប់រំ" ។ កាលទិវាអក្ខរកម្មពិភព សម្តេចប្រមុខរាជរដ្ឋាភិបាល ក៏បានអំពាវនាវឱ្យគ្រប់ស្ថាប័នទាំងអស់រួមសហការគ្នាក្នុងការជម្រុញផែនការនេះឱ្យបានសម្រេច ។

តាមតួលេខរបស់ក្រសួងអប់រំយុវជននិងកីឡា ក៏បានបង្ហាញថា មានអ្នកដែលមិនចេះអក្សរចំនួនប្រមាណ ២លាននាក់ គឺប្រមាណជា ២២,៧% នៃប្រជាជនសរុប ។ តួលេខនេះគឺច្រើនណាស់ ដែលវាទាមទាឱ្យយើងទាំងអស់គ្នាចូលរួមយ៉ាងសកម្មដើម្បីកាត់បន្ថយអត្រាអនក្ខរភាពក្នុងសង្គមកម្ពុជាយើង ។

តើធ្វើយ៉ាងណាដើម្បីចូលរួម ? មាតាបិតាទាំងអស់ត្រូវនាំកូនរបស់ខ្លួនដែលគ្រប់អាយុទៅចុះឈ្មោះចូលរៀន ។ គឺដូចគ្នាដែរសម្រាប់និយោជក ដែលមាននិយោជិតជាកុមារគឺត្រូវផ្តល់ឱកាសឱ្យគេបានរៀនសូត្រដើម្បីឱ្យគេមានសមត្ថភាពក្នុងការអាន និងសរសេរអក្សរផងដែរ ។

តាមជំនឿព្រះសហគមន៍កាតូលិក យើងជឿថា ជីវិតរបស់មនុស្សមានតម្លៃដូចគ្នា មានសេចក្តីថ្លៃថ្នូរ មិនថាជា អ្នកមាន អ្នកក្រ អ្នកងារ អ្នកជា នយោជក ឬមួយនយោជិតនោះទេ ។ មនុស្សទាំងអស់ជាបងប្អូននឹងគ្នា ជាបុត្រធីតានៃព្រះជាម្ចាស់ជាបិតាតែមួយ ជាពិសេស ព្រះជាម្ចាស់ប្រទានឱ្យមនុស្សទាំងអស់មានវប្បធម៌ មានអារ្យធម៌ ភាសា និងអក្សរសាស្ត្រ...។ ដូច្នេះមនុស្សត្រូវថែរក្សាវប្បធម៌-ភាសា ដែលខ្លួនមានដោយយកចិត្ត ទុកដាក់បន្តឱ្យកូនចៅគ្រប់ជំនាន់ ។

ការផ្តល់ឱកាសឱ្យកុមារទទួលការអប់រំ ជាមតិកដ៏ប្រសើរបំផុតសម្រាប់អនាគតរបស់ពួកគេរបស់សហគមន៍ និងសង្គមកម្ពុជាទាំងមូល ដែលពោរពេញដោយអ្នកមានចំណេះដឹង និងមានសមត្ថភាព ដែលជាធនធានដ៏ឧត្តមសម្រាប់ការអភិវឌ្ឍប្រទេសជាតិឱ្យក្លាយទៅជាអារ្យប្រទេសមួយផងដែរ ។

## កម្មវិធីវិទ្យុព្រះសហគមន៍កាតូលិក

### អ្នកចូលរួមកម្មវិធីអេម៉ានូអែល "សម្លេងពីព្រះសហគមន៍កាតូលិក" ខែតុលា

-ថ្ងៃអាទិត្យ ទី០៣ ខែតុលា ឆ្នាំ២០១០ : អាទិត្យទី២៧ ក្នុងរដូវធម្មតាចូលរួមដោយបងស្រី គឹក សុខលីន មកពីព្រះសហគមន៍កំពង់ធំនៃភូមិភាគបាត់ដំបង។

-ថ្ងៃអាទិត្យ ទី១០ ខែតុលា ឆ្នាំ២០១០ : អាទិត្យទី២៨ ក្នុងរដូវធម្មតា ចូលរួមដោយ លោកបូជាចារ្យម៉ែត វិន័យ មកពីព្រះសហគមន៍កំពង់ធំនៃភូមិភាគបាត់ដំបង។

-ថ្ងៃអាទិត្យទី១៧ ខែតុលា ឆ្នាំ២០១០ : អាទិត្យទី២៩ ក្នុងរដូវធម្មតា ចូលរួមដោយលោកបូជាចារ្យ ដូស៊ី ពីព្រះសហគមន៍ចំការទៀងនៃភូមិភាគភ្នំពេញ។

-ថ្ងៃអាទិត្យទី២៦ ខែតុលា ឆ្នាំ២០១០ : អាទិត្យទី៣០ ក្នុងរដូវធម្មតា ចូលរួមដោយលោកបូជាចារ្យតូតែត ពីព្រះ សហគមន៍បាត់ដំបងនៃភូមិភាគបាត់ដំបង។

-ថ្ងៃអាទិត្យទី៣១ ខែតុលា ឆ្នាំ២០១០ : អាទិត្យទី ៣១ ក្នុងរដូវធម្មតា ចូលរួមដោយលោកអភិបាល អែនរីគេ ហ្វីហ្គារេដូ អភិបាលភូមិភាគបាត់ដំបង។

### "ខ្ញុំត្រូវការអ្នក" ខែតុលា (FM 99.5 Mhz ច័ន្ទ,អង្គារ ម៉ោង១០-១១ព្រឹក)

ថ្ងៃទី០៤ តុលា : ចរាចរណ៍ក្នុងឱកាសបុណ្យភ្ជុំ។ ថ្ងៃទី០៥ តុលា : ផឹកបើកៗ។ ថ្ងៃទី១០ តុលា : អាណាព្យាបាលគួរជំរុញឱ្យយុវវ័យស្រឡាញ់ការសិក្សា។ ថ្ងៃទី១១ តុលា : គ្រូបង្រៀនជាចលករសំខាន់ជំរុញយុវវ័យឱ្យស្រឡាញ់ការសិក្សា។ ថ្ងៃទី១៨ តុលា : កល្យាណមិត្ត។ ថ្ងៃទី១៩ តុលា : ជម្នះឧបសគ្គក្នុងការសិក្សា។ ថ្ងៃទី២៤ តុលា : យុវជននិងការស្វែងរកអាហារូបករណ៍។ ថ្ងៃទី២៥ តុលា : យុវជន និងការស្វែងរកប្រភពព័ត៌មានទីផ្សារការងារ។ សូមបញ្ជាក់ថា ប្រធានបទទាំងនេះនឹងមានការចូលរួមបកស្រាយពីវាគ្មិនដែលមានបទពិសោធន៍ និងជំនាញច្បាស់លាស់។**សូមកុំភ្លេចតាមដាន!**

**ការិយាល័យព័ត៌មានកាតូលិក**
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់
បឹងព្រលិត ខណ្ឌ ៧ មករា រាជធានី ភ្នំពេញ
Tel/Fax : (855) 23 224 120;
E-mail : csccambodia@gmail.com
Website : www.catholiccambodia.org
អ្នកសម្របសម្រួល : លោកស្រីប្រាម៉ុង វីរជ័យ ។ ប្រធាន : លោកលី សុវណ្ណា ។
Licence ១៨៣ ពម.ប្រក. / ២៥-មិថុនា-២០០៧

**សម្តេចប៉ាបបេណេឌីក ទី១៦ បានទទួលយកសំណើលាឈប់ពីមុខងារជាអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញរបស់លោកអភិបាល អេមីល ដេតម្បូខ សម្តេចប៉ាបបានអនុញ្ញាតឱ្យលោកចូលនិវត្តន៍តាមព្រះវិន័យ ដែលបានកំណត់ខ លោកអូលីវីយេ ឝ្មិតហាស្លេ បច្ចុប្បន្នមានតួនាទីជាអភិបាលឧបត្ថម្ភកៈនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ នឹងត្រូវទទួលមុខងារជាអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ បន្តពីលោកអភិបាល អេមីល ដេតម្បូ ចាប់ពីថ្ងៃទី១ ខែ តុលា ឆ្នាំ២០១០ វេលា ម៉ោង ៥:០០ រសៀលតទៅខ**

# សេដ្ឋកិច្ច

## ផលិតផលកសិកម្មខ្មែរពីរប្រភេទចាប់ផ្ដើមមានទីផ្សារ

**ខាន់ ភីរម្យ**

"មកដល់ពេលបច្ចុប្បន្ននេះ ផលិតផលកសិកម្មខ្មែរយ៉ាងហោចណាស់២មុខដែរ បានចាប់ផ្ដើមមានទីផ្សារនៅក្រៅប្រទេសជាបណ្ដើរៗ"។ នេះបើតាមការអះអាងរបស់ផលិតករនៅក្នុងស្រុក។

ផលិតផលអាហារកែច្នៃទាំងពីរមុខនោះ គឺរួមមានស្ករត្នោតសរីរាង្គ និងផលិតផលម្រេចកំពត។

លោកសំ សារឿន ប្រធានសមាគមលើកកម្ពស់ស្ករត្នោតកំពង់ស្ពឺ មានប្រសាសន៍ថា នៅក្នុងឆ្នាំនេះសមាគមអាចផលិតស្ករត្នោតសរីរាង្គបានចំនួន៣១តោន និងក៏ត្រូវបានលក់ចេញទៅបីក្រុមហ៊ុន ដែលក្រុមហ៊ុនមួយ អាចមានលទ្ធភាព នាំចេញទៅកាន់ប្រទេសម៉ាឡេស៊ី អូស្ត្រាលី និងប្រទេសបារាំង។

ចំណែកលោកឈេន រ៉ារុធ មន្ត្រីក្រុមហ៊ុន ខុនហ្វីរ៉ែល ដែលជាក្រុមហ៊ុននាំចេញផ្ទាល់នោះបានឱ្យដឹងថា ទីផ្សារស្ករត្នោតនៅក្រៅប្រទេស នាពេលកន្លងមក មានតែនៅបារាំងទេ។ ហើយបរិមាណនៃការនាំចេញ គឺមិនមានការកើនឡើងឡើយ។ សម្រាប់ទីផ្សារប្រទេសផ្សេងៗ ដូចជាម៉ាឡេស៊ី គឺកំពុងតែសាក ល្បង ហើយអូស្ត្រាលីក៏ជាឆ្នាំទី១ ដែរ។

ក្រៅពីស្ករត្នោតកំពង់ស្ពឺ ម្រេចកំពត ក៏ជាទំនិញកសិកម្មមានសក្ដានុពលមួយនៅលើទីផ្សារនាំចេញរបស់កម្ពុជាផងដែរ។


Photo : S. Philong

លោកងួន ឡាយ ប្រធានសមាគម ម្រេចកំពត បានមានប្រសាសន៍កាលពីថ្ងៃទី១៥ ខែកញ្ញា កន្លងទៅនេះថា បើតាមប្រជាប្រិយភាពរបស់ម្រេចខេត្តកំពត គឺមានទីផ្សារច្រើននៅឯក្រៅប្រទេស។ ប៉ុន្តែបញ្ហា ដែលធ្វើឱ្យបរិមាណការនាំចេញម្រេចកំពតមិនបានច្រើននោះ ដោយសារតែម្រេចដែលកំពុងតែប្រមូលផលនោះគឺជាម្រេចដើមចាស់ៗ។

លោកងួន ឡាយ បន្តថា ម្រេចកំពតដែលកំពុងតែប្រមូលផលនោះ គឺមានត្រឹមតែ ៩,៧៥ ហិកតាតែប៉ុណ្ណោះ។ ជាមួយនឹងផ្ទៃដីដែលមានស្រាប់នេះក្នុងមួយឆ្នាំ ម្រេចកំពតឱ្យផលប្រមាណ ១៧តោន ហើយផលិតផលម្រេច ដែលអាចនឹងគ្រប់ ហើយត្រូវស្តង់ដារសម្រាប់នាំចេញនោះ គឺមានប្រមាណ ១០តោន ក្រៅពីនោះ ៧តោនទៀត គឺសម្រាប់តែប្រើប្រាស់នៅក្នុងស្រុក។

### ម្រេចកំពត និងស្ករត្នោតកំពង់ស្ពឺ ជាទំនិញចុះបញ្ជីស្របច្បាប់

ម្រេចកំពត និងផលិតផលស្ករត្នោតកំពង់ស្ពឺ គឺជាទំនិញពីរប្រភេទដែលបានចុះបញ្ជីជាផលិតផលសម្គាល់ភូមិសាស្ត្រនៅក្រសួងពាណិជ្ជកម្មរួចរាល់ហើយ។

លោកងួន ឡាយ ប្រធានសមាគមម្រេចកំពតបានឱ្យដឹងថា យើងបានចុះបញ្ជីផលិតផលទាំងពីរនេះជាទំនិញសម្គាល់ភូមិសាស្ត្ររួចរាល់ហើយទៅថ្ងៃអនាគតយើងយល់ថា ផលិតផលទំនិញរបស់យើង គឺជាផលិតផលទំនិញមួយដែលប្រកបដោយសក្តានុពលជាមិនខាន។

ចំណែកលោកសំ សារឿន ជាប្រធានសមាគមលើកកម្ពស់ស្ករត្នោតកំពង់ស្ពឺ បានមានប្រសាសន៍ឱ្យដឹងដែរថា សម្រាប់ការចុះបញ្ជីនេះ គឺដើម្បីជំរុញឱ្យផលិតផលរបស់យើងឱ្យមានស្តង់ដារ និងដើម្បីជំរុញការនាំចេញទៅកាន់ទីផ្សារនៅក្រៅប្រទេសបាន។

ផលិតផលម្រេចដែលសមាគមនាំចេញនោះ គឺមានបីប្រភេទ : ប្រភេទទីមួយ តម្លៃថោកជាងគេនោះ គឺម្រេចខ្មៅ មានតម្លៃមួយគីឡូក្រាម ស្មើនឹង ៥,៧៥ដុល្លារ។ ប្រភេទទីពីរ ម្រេចក្រហមក្នុងមួយគីឡូក្រាមមានតម្លៃ ១០,៥០ដុល្លារ ហើយប្រភេទទីបីនោះ គឺម្រេចសដែលមានតម្លៃថ្លៃជាងគេ ១២,៥០ដុល្លារ ក្នុងមួយគីឡូក្រាម។

# សុខភាព

## គ្រូពេទ្យឯកទេស : "បើគ្មានករណីចាំបាច់ ស្ត្រីគួរសម្រាលកូនតាមធម្មជាតិ"

**ជាត សំភី**

លោកលី ចន្ទរិទ្ធ គ្រូពេទ្យឯកទេសសម្ភព និងរោគស្ត្រី និងជាអនុប្រធានមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត មានប្រសាសន៍ថា ការសម្រាលកូនដោយវះកាត់ ឬការវះយកកូន គេអាចធ្វើតាមស្ថានភាពជាក់ស្តែងដែលគ្រូពេទ្យគិតថា បើធ្វើការវះកាត់គេអាចទទួលកូនបានរស់ ហើយម្តាយបានផុតពីគ្រោះថ្នាក់។ រីឯការកំណត់តាមបច្ចេកទេសនោះ គឺគ្រូពេទ្យឯកទេសសម្ភពទាំងអស់សុទ្ធតែដឹង។

ទោះជាយ៉ាងណា លោកលី ចន្ទរិទ្ធ បញ្ជាក់ថា : "បើមិនចាំបាច់ ស្ត្រីគួរសម្រាលកូនតាមក្រោម ឬតាមធម្មជាតិ"។ លោកលី ចន្ទរិទ្ធ ក៏មានប្រសាសន៍ដែរថា បើមិនមានបញ្ហាអ្វី ហើយស្ត្រីអាចកើតកូន


Photo : S. Philong

តាមធម្មជាតិបាន គឺគាត់អាចផ្តល់កំណើតកូនរហូតដល់ ១០បាន បើគាត់ចង់។ ប៉ុន្តែបើគាត់វះកាត់ គឺគាត់អាចវះបានតែបីដងទេ។

លោកគ្រូពេទ្យ ក៏មានប្រសាសន៍បន្តថា សម័យឥឡូវ ស្ត្រីមួយចំនួនគឺចង់ទទួលការវះកាត់យកកូនច្រើនជាងឈឺពោះ សម្រាលដោយសារ ទីមួយគាត់មិនចង់ឈឺពោះព្រោះឈឺពោះម្តងៗជួនកាលយូរ។ ទីពីរ គាត់អាចមានគំនិតថាទាល់តែធ្វើការ វះកាត់ទើបកូនរបស់គាត់ អាចមានបញ្ញា មានសុខភាពល្អ ឬគាត់ចង់រក្សាសរីរាង្គរបស់គាត់ជាដើម។ ប៉ុន្តែស្ត្រីគួរពិចារណាឡើងវិញថា ការសម្រាលកូនជាក្រឹត្យក្រមធម្មជាតិ។ ម្យ៉ាងទៀតការវះកាត់ទៀតសោតសូមកុំសុទ្ធតែរំពឹងថា វានឹងពុំមានបញ្ហាសោះនោះឡើយ។ ជាក់ស្តែងតាមធម្មតា គេតម្រូវឱ្យចុះហត្ថលេខាមុនពេលវះកាត់។

លោកគ្រូពេទ្យ ក៏អះអាងថា ការវះកាត់ដើម្បីយកកូនស្ត្រីអាចធ្វើបាន។ ប៉ុន្តែគាត់ត្រូវសុំការណែនាំ ឬដំបូន្មានពីគ្រូពេទ្យឯកទេសសិនពីផលវិបាក និងផលប៉ះពាល់របស់វា។

MesOctober-2010 OK.qxd 10/4/2010 4:46 PM Page 5





Photo : S. Philong

# យុវជនត្រូវស្គាល់តម្លៃនៃការប្រើប្រាស់អ៊ីនធឺណិត

**ខាន់ ភីរម្យ**

អ៊ីនធឺណិតគឺជាឃ្លាំងចំណេះដឹង និងក៏ជាប្រភពទំនាក់ទំនងមួយដ៏សំខាន់នៅក្នុងយុគសម័យនៃការរីកចម្រើននៃវិស័យបច្ចេកវិទ្យាព័ត៌មាន។

យុវជនមឿន រតនា អតីតនិស្សិតផ្នែកព័ត៌មានវិទ្យានៅសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានប្រាប់ថា សព្វថ្ងៃនេះអ៊ីនធឺណិតគឺជាឃ្លាំងមេរៀន និងចំណេះដឹងរបស់ប្អូន។ រតនាក៏បានបញ្ជាក់ថា : "ខ្ញុំប្រើប្រាស់ អ៊ីនធឺណិតសឹងតែរាល់ថ្ងៃដើម្បីមើលព័ត៌មាន និងរកការងារ..."។

តាមការអះអាងរបស់រតនា ចំណាប់អារម្មណ៍ និងការចូលចិត្តប្រើប្រាស់នូវប្រព័ន្ធអ៊ីនធឺណិតរបស់លោកនាពេលបច្ចុប្បន្ននេះ គឺដើម្បីតាមដានមើលព័ត៌មាន ដែលកើតមានឡើងជាប្រចាំថ្ងៃ និងស្វែងរកឯកសារដែលមានប្រយោជន៍ដល់ការសិក្សាជាដើម។ ហើយគេហទំព័រដែលលោកតែងតាមដានជាប្រចាំថ្ងៃនោះ គឺមានគេហទំព័រព័ត៌មានអូស្ត្រាលី វិទ្យុបារាំង-ល-។ រតនាបានបញ្ជាក់ថា : "អ៊ីនធឺណិតមិនមែនត្រឹមតែជួយខ្ញុំឱ្យដឹងអំពីបញ្ហាសង្គមទេ ថែមទាំងអាចឱ្យខ្ញុំ ស្វ័យសិក្សាភាសាអង់គ្លេសរបស់ខ្ញុំដែរ"។ លោកបានឱ្យដឹងថា អ៊ីនធឺណិត ជួយយើងបានច្រើនណាស់ វាអាចឱ្យយើងដឹងពីសង្គមដោយខ្លួនយើងផ្ទាល់ ហើយអាចឱ្យយើងស្រាវជ្រាវរកដំណោះស្រាយបានច្រើនផងដែរ នៅពេលដែលយើងមានបញ្ហា ឬឧបសគ្គណាមួយ។

សម្រាប់យុវជនម្នាក់ទៀត ដែលបច្ចុប្បន្នកំពុងសិក្សាបរិញ្ញាបត្រព័ត៌មានវិទ្យា ឆ្នាំទី៣ នៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ ឈ្មោះថន វិសាល បានឱ្យដឹងថា អ៊ីនធឺណិតក្រៅពីជួយលោក ឱ្យស្វ័យសិក្សាដោយខ្លួនឯងហើយនោះ វាអាចជួយឱ្យលោកមានឱកាសធ្វើការទំនាក់ទំនងជាមួយមិត្តភក្តិនិងសង្គមខាងក្រៅបានធំទូលាយទៀត។

វិសាលបានបញ្ជាក់ថា: "អ៊ីនធឺណិតទូលំទូលាយណាស់ យើងនៅកម្ពុជា តែយើងអាចស្វែងរកមើលឯកសារនៅទីណាក៏បាន បើយើងចង់ស្វែងយល់"។

សព្វថ្ងៃនេះ វិសាលបានស្គាល់គេហទំព័រ លើសពី១០។ តែគេហទំព័រដែលវិសាលនិយមប្រើប្រាស់ជាងគេនោះ គឺមានហ្គូហ្គល **www.google.com** និងគេហទំព័រថ្មីមួយ ដែលលោកទើបតែរកឃើញ ហើយវាសំបូរឯកសារដែរនោះ គឺគេហទំព័រដើម្បីមើលសៀវភៅ **www.bookboon.com**។

ក្រៅពីយុវនិស្សិតទាំងពីររូបខាងលើ កុមារីវ័យត្រឹមតែ ១៣ឆ្នាំមួយរូប ដែលកំពុងសិក្សានៅថ្នាក់ទី៨ វិទ្យាល័យព្រះយុគន្ធរ រាជធានីភ្នំពេញ ឈ្មោះស្រីពៅ ក៏ទទួលស្គាល់នូវអត្ថប្រយោជន៍នៃការប្រើប្រាស់អ៊ីនធឺណិតដែរ។ ស្រីពៅបានបញ្ជាក់ដែរថា : "អ៊ីនធឺណិតល្អ និងស្រួលណាស់"។ យោងតាមការរៀបរាប់របស់ស្រីពៅ អ៊ីនធឺណិតអាចឱ្យនាងមើលព័ត៌មាន ឬលេងឆាត(Chat) ឬជជែកលេង ដែលជាឧបករណ៍ទំនាក់ទំនងដ៏ពេញនិយម ហើយអាចរៀនមើលមេរៀនភាសាអង់គ្លេសថែមទៀតផង។

ស្រីពៅបានឱ្យដឹងដែរថា : "បងខ្ញុំគាត់នៅក្រៅប្រទេស។ តែខ្ញុំអាចឆាតជាមួយគាត់ អស់លុយតែបន្តិចទេ ហើយអាចឮនូវសម្លេង និងបានឃើញមុខគាត់ថែមទៀតផង"។

គេហទំព័រដែលស្រីពៅកំពុងតែប្រើប្រាស់នៅពេលនេះ គឺមានដូចជា **www.northstar.com** និង www.longman.com ឬ Yahoo messenger និង Facebookជាដើម។

ទន្ទឹមនឹងសារៈប្រយោជន៍ចំពោះការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត យុវជនរតនាដែលមានភាពចាស់ទុំបន្តិចនោះ បានលើកមតិថា ប្រព័ន្ធអ៊ីនធឺណិតពិតជាមានគុណសម្បត្តិច្រើនមែន។ ប៉ុន្តែទន្ទឹមនឹង នេះអ៊ីនធឺណិតក៏អាចមាននូវគុណវិបត្តិខ្លះៗដែរ។

រតនាបានបញ្ជាក់ដែរថា : "អ៊ីនធឺណិតមានគេហទំព័រល្អៗមានប្រយោជន៍។ ទោះយ៉ាងណា វាក៏សម្បូរនូវគេហទំព័រ ដែលធ្វើឱ្យយើងខាតពេល ប៉ះពាល់អារម្មណ៍ និងជំរុញឱ្យយើងដើរផ្លូវអាក្រក់ក៏មានដែរ។ ដូច្នេះយើងត្រូវតែប្រុងប្រយ័ត្ន"។

MesOctober-2010 OK.qxd 10/4/2010 4:46 PM Page 6

## កសិកម្ម

# ការដាំស្មៅ ប្រែរបៀបចិញ្ចឹមគោ ឱ្យបានទិន្នផលខ្ពស់

**ជាត សំភី**


Photo : P. Nith

តាមប្រសាសន៍របស់លោកបណ្ឌិត ឈុំ ផិតលន់ ព្រឹទ្ធបុរសនៃមហាវិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វ នៅឯសកលវិទ្យាល័យភូមិន្ទកសិកម្មចំការដូង បានមានប្រសាសន៍ថា ការដាំស្មៅឱ្យគោស៊ីគឺមានសារៈសំខាន់ នៅពេលបច្ចុប្បន្ននេះ ពីព្រោះវាផ្តល់សារៈប្រយោជន៍ច្រើន សម្រាប់ប្រជាកសិករ។

លោកបណ្ឌិត បានមានប្រសាសន៍ថា ស្មៅដែលលោកចង់ណែនាំដល់ប្រជាកសិករដាំនេះ គឺជាស្មៅស្តេច។ ស្មៅនេះជាស្មៅនាំចូល និងដាំដើម្បីចិញ្ចឹមគោនៅកន្លែងពិសោធន៍ខ្លះៗ។ ប៉ុន្តែវាគឺជាប្រភេទស្មៅដែលលូតលាស់លឿន ពោលគឺដាំតែត្រឹមរយៈពេលបី ឬបួន អាទិត្យ វាអាចលូតលាស់ពី ១ម៉ែត្រ ទៅ ១ម៉ែត្រកន្លះ និងវាឱ្យផលចំនួន ២២តោន ក្នុង ១ហិចតា។ ដូច្នេះបើកសិករដាំក្នុង ១ហិចតា គាត់អាចចិញ្ចឹមគោបានរហូតដល់ពី១០ ទៅ ២០ក្បាល ដោយសារគាត់អាចធ្វើការច្រូតវិលជុំ។

លោកបណ្ឌិតមានប្រសាសន៍បន្តថា ការដាំស្មៅនេះ វាមិនមានការលំបាកអ្វីនោះទេ។ កសិករអាចភ្ជួរដីជម្រៅ ២០ សង់ទីម៉ែត្រ រួចលើកជារងបន្ទាប់មកគាត់អាចយកពូជស្មៅនេះទៅដាក់ និងបង្ហូរទឹកដាក់ ដើម្បីឱ្យស្មៅស្រូបយកទឹកនោះ។ កសិករគួរប្រើជីកំប៉ុស្ត ឬក៏ជីអាមច៌សត្វ ដើម្បីជំរុញការលូតលាស់របស់ស្មៅ។ ប្រសិនបើគាត់ប្រើជីគីមី វាអាចធ្វើខូច ដីទៅថ្ងៃក្រោយ។ សម្រាប់ស្មៅនេះ កសិករគួរចាប់ផ្តើមដាំស្មៅនេះនៅរដូវខែវស្សា ពីព្រោះវាសម្បូរទឹក។ បើគាត់ដាំនៅរដូវប្រាំង គាត់អាចធ្វើបាន ប៉ុន្តែត្រូវបាចទឹកឱ្យបានគ្រប់គ្រាន់។ ចំណែកដីដែលដាំត្រូវនឹងស្មៅនេះ គឺជាប្រភេទ ដីល្បាប់ទើបស្មៅលូតលាស់បានល្អ។

នៅពេលសព្វថ្ងៃនេះ ពូជស្មៅស្តេចនេះ កសិករអាចស្វែងរកបាននៅសកលវិទ្យាល័យភូមិន្ទកសិកម្មចំការដូង រាជធានីភ្នំពេញ ឬនៅភ្នំតាម៉ៅ។

លោកបណ្ឌិត ឈុំ ផិតលន់ បញ្ជាក់ថា នាពេលសព្វថ្ងៃនេះ ការចិញ្ចឹមសត្វ មានការរីកចម្រើន ជាពិសេសគោ។ ដូច្នេះតម្រូវការស្មៅ ក៏កាន់តែច្រើនដែរ។ បើកសិករសង្ឃឹមទៅលើការឃ្វាលគោ ទៅស៊ីតាមវាល ដែលភាគច្រើនជាប្រភេទស្មៅបារាំងនោះវាមិនគ្រប់គ្រាន់នោះឡើយ។ ម្យ៉ាងទៀតគោរបស់គាត់ ក៏អាចឆ្លងជំងឺនានាផងដែរ។ ដូច្នេះគាត់គួរគិតគូរដាំស្មៅ។ លោកបណ្ឌិត ក៏បានគូសបញ្ជាក់ទៀតថា បើកសិករអាចដាំស្មៅស្តេចឱ្យគោស៊ីនេះនឹងធ្វើឱ្យគោរបស់គាត់មានសុខភាពល្អ ព្រោះស្មៅដាំមានអនាម័យ ហើយបើចិញ្ចឹមគោយកទឹកដោះក៏ឱ្យទិន្នផលល្អដែរ។ ដាំស្មៅធ្វើឱ្យកសិករ ចំណេញពេលដោយមិនបាច់ឃ្វាល និងប្រើនូវកម្លាំងមនុស្សច្រើន។ ដូច្នេះកសិករអាចរកចំណូលបន្ថែម ដើម្បីជួយទ្រទ្រង់សេដ្ឋកិច្ចគ្រួសារ។

## បរិស្ថាន

# ព្រៃឈើស្រូបយកកាបូនកាន់តែតិចទៅៗ គួរឱ្យព្រួយបារម្ភ

យោងតាមសារព័ត៌មានបារាំង ឡឺ ហ្វីការ៉ូ បានឱ្យដឹងថា ការស្តុកជាធម្មជាតិនៃឧស្ម័នកាបូនិកនៅក្នុងរុក្ខជាតិបានថយចុះតាំងតែពីឆ្នាំ២០០០។ នេះបង្ករឱ្យមានផលវិបាកនៃការកើនកម្តៅនៃផែនដីដែលធ្វើឱ្យអ្នកវិទ្យាសាស្ត្រមានការព្រួយបារម្ភ។

"ការស្រាវជ្រាវបង្ហាញលទ្ធផលទាំងភ្ញាក់ផ្អើល និងគួរឱ្យព្រួយបារម្ភ។ ព្រៃឈើបន្ថយនូវការស្រូបយកឧស្ម័នកាបូនិច។ រយៈ១០ឆ្នាំ កន្លងមកហើយ បរិមាណ នៃការស្រូបយកឧស្ម័នកាបូនិចជាធម្មជាតិថយចុះពុំឈប់ឈរ"។ នេះបើតាមការពន្យល់របស់អ្នកស្រាវជ្រាវពីរនាក់នៅសកលវិទ្យាល័យម៉ុងតាណាសហរដ្ឋអាម៉េរិក។ពួកលោកបានឱ្យដឹងថា រុក្ខជាតិផ្ទុកសារជាតិ (ក្លរ៉ូភីល) ដែលអាចឱ្យរុក្ខជាតិ ស្រូបយកកាបូនបរិយាកាស និងបញ្ចេញមកវិញនូវឧកស៊ីសែន ដោយប្រើថាមពលពន្លឺព្រះអាទិត្យធ្វើសំយោគ។ នេះជាការដកដង្ហើមរបស់រុក្ខជាតិសម្រាប់ការលូតលាស់របស់ខ្លួន។

នៅឆ្នាំ២០០៧ មនុស្សជាតិបានបំភាយនៅក្នុងបរិយាកាសប្រមាណ ៧,៩កោដិតោន នូវកាបូន។ តួលេខនេះកើតឡើងជារៀងរាល់ឆ្នាំ។ ប្រសិនបើការស្រូបយកនូវកាបូនធម្មជាតិត្រូវធ្លាក់ចុះទន្ទឹមពេលគ្នានោះ ល្បឿននៃការកើនកម្តៅនៃផែនដីក៏កាន់តែកើន។ នេះជាអ្វីដែលបង្កើនគ្រោះរាំងស្ងួតដែលបន្ថយការស្រូបយកកាបូនរបស់រុក្ខជាតិ។ វាជាអ្វីដែលគេហៅថា វដ្តនៃដំណើរខូចខាត។

**ឯកសារស្រាវជ្រាវ**


Photo : S. Phiong

MesOctober-2010 OK.qxd 10/4/2010 4:46 PM Page 7



# ដោយសារជំនាញកាត់សក់មនុស្សថ្លង់អាចទីពឹងខ្លួនឯងបានក្នុងសង្គម

**ជាត សំភី**

អ្នកខ្លះកាន់កន្ត្រៃ។ អ្នកខ្លះទៀតកាន់ត្រង់ដឹ។ ពួកគេកំពុងតែរៀនកាត់សក់ឱ្យគ្នាទៅវិញទៅមកម្តងម្នាក់នៅក្នុងថ្នាក់បង្រៀនកាត់សក់មួយនៅក្នុងក្របខណ្ឌនៃកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈរបស់អង្គការម៉ារីណុល។ វគ្គបណ្តុះបណ្តាលកាត់សក់នេះត្រូវបានបង្កើតឡើងតាំងពីថ្ងៃទី១ ខែកក្កដា នាឆ្នាំ២០១០ កន្លងទៅ។

សិស្ស ១០នាក់ កំពុងអនុវត្តជាក់ស្តែងនូវទ្រឹស្តីកាត់សក់ដែលពួកគេបានរៀន ក្នុងផ្ទះមួយ នៅក្នុងសង្កាត់បឹងត្របែក ខណ្ឌចំការមន ទីក្រុងភ្នំពេញ។




ទោះបីជាគាត់ទំនាក់ទំនងគ្នាបានតែតាមកាយវិការ តែគាត់អាចផ្ចិតផ្ចង់បញ្ចេញថ្វីដៃកាត់សក់បានយ៉ាងស្អាតផងដែរ។

លោកហុង គឹមហាក់ ជាប្រធានគម្រោងអភិវឌ្ឍន៍ជំនាញនៃកម្មវិធីអភិវឌ្ឍន៍មនុស្សថ្លង់នៅអង្គការម៉ារីណុល បានមានប្រសាសន៍ថា: "មនុស្សថ្លង់មានសមត្ថភាពយ៉ាងពេញលេញក្នុងការការប្រកបអាជីពកាត់សក់នេះ"។

លោកហុង គឹមហាក់ មានប្រសាសន៍ដែរថា : "កម្មវិធីមានគោលបំណងជំរុញមនុស្សថ្លង់ឱ្យមានលទ្ធភាពប្រកបអាជីព"។ លោកបានបន្តថា ដូច្នេះយើងបង្រៀនពួកគេនូវជំនាញពិតប្រាកដ។ យើងបានផ្តល់ឱ្យពួកគេនូវការយល់ដឹងអំពីសង្គមខ្មែរដូចជាវប្បធម៌ និងរបៀបរស់នៅ។ យើងបានគាំទ្រមនុស្សថ្លង់ទៅក្នុងសង្គម។ ជាលទ្ធផល ពួកគេអាចដាក់ពាក្យរកការងារបាន ដោយគ្មានការរើសអើងឬមួយគ្រប់គ្រងជាជីវកម្មផ្ទាល់ខ្លួនរបស់ពួកគេ។

សិស្សដែលចង់ចូលរៀនកាត់សក់ គឺត្រូវតែមានអាយុលើសពី ១៨ឆ្នាំ។ ពួកគេ ត្រូវមានចំណង់ចង់ធ្វើការនេះពិតប្រាកដ។ពួកតែឆ្លងកាត់ការធ្វើតេស្តជ្រើសរើសមុននឹងសិក្សាជំនាញ។ ទាំងអស់គ្នាមកពីសាលាភាសាសញ្ញានៃអង្គការម៉ារីណុល។ ពួកគេកំពុងតែសិក្សាជំនាញតាមរយៈការបកប្រែភាសាសញ្ញា។ គ្រូកាត់សក់អាជីពម្នាក់ និងអ្នកគ្រូបកប្រែភាសាសញ្ញាម្នាក់ គឺកំពុងបង្រៀនពួកគេនៅក្នុងវគ្គសិក្សារយៈពេលមួយឆ្នាំ។

លោកហុង គឹមហាក់ មានប្រសាសន៍ថា ពីមុនអង្គការម៉ារីណុល គឺបានបំពេញការបណ្តុះបណ្តាលជំនាញកាត់សក់បាន២វគ្គ។ ប៉ុន្តែយើងគ្រាន់តែបានបញ្ជូនកូនសិស្ស ឱ្យទៅរៀនជាមួយអង្គការដៃគូ។ ប៉ុន្តែឥឡូវម៉ារីណុលក៏បានបង្កើតវគ្គបណ្តុបណ្តាលកាត់សក់នេះដោយខ្លួនឯង។

អង្គការម៉ារីណុលផ្តល់ទីស្នាក់អាស្រ័យនិងចំណីអាហារដល់សិស្សរៀនកាត់សក់នេះ។ ហើយបន្ទាប់ពីរៀនចប់ សិស្សខ្លះអាចទទួលប្រាក់ពី១៧០ដុល្លារដល់២០០ដុល្លារ ដែលអាស្រ័យតាមកម្រិតជីវភាពរបស់ពួកគេ ពីកម្មវិធី ដើម្បីទិញសម្ភារៈចាប់ផ្តើមអាជីវកម្មនៅតាមភូមិស្រុករបស់ពួកគេ។ ប៉ុន្តែខ្លះទៀតទៅធ្វើការនៅតាមហាងកាត់សក់នានា។

លោកហុង គឹមហាក់ រៀបរាប់បន្តថា បន្ទាប់ពីការសិក្សាបានបីខែ សិស្សរបស់ម៉ារីណុលអាចអនុវត្តជាក់ស្តែងលើការកាត់សក់អតិថិជន ដូចជាកាត់សក់កូនសិស្ស អ្នករត់ម៉ូតូឌុប ក៏ដូចជាកូនរបស់អ្នកក្រីក្រជាដើម។ អតិថិជនបានវាយតម្លៃអំពីសមត្ថភាពរបស់សិស្សទាំងនេះថា ល្អប្រសើរ។ សម្រាប់ការកាត់សក់នេះ សិស្សទទួលបាន១០០០រៀលក្នុងមនុស្សម្នាក់។ លុយនេះគ្រាន់តែប្រើប្រាស់សម្រាប់ទិញសម្ភារៈត្រឡប់មកវិញប៉ុណ្ណោះ។

គឹម សៀងលីជាយុវជនអាយុ ១៨ឆ្នាំ និយាយតាមរយៈអ្នកបកប្រែភាសាថា : "ខ្ញុំមានអារម្មណ៏សប្បាយរីករាយដោយបានសិក្សាវិជ្ជាជីវៈកាត់សក់



នេះ។ កាលពីមុន ខ្ញុំបានស្នាក់នៅតែផ្ទះ ដោយគ្មានការទំនាក់ទំនងជាមួយនិងអ្នកដទៃឡើយ។ ខ្ញុំមានអារម្មណ៏សោកសៅណាស់។ ប៉ុន្តែឥឡូវខ្ញុំមានការរីកចម្រើនច្រើនទាំងចំណេះដឹងសង្គម និងអាជីព។ ខ្ញុំមានសង្ឃឹមថ្មីឡើងវិញ"។

យុវជនពិន ដាំ អាយុ ១៨ឆ្នាំ បាននិយាយដែរថា គាត់រីករាយដែរ។ ជាមួយនិងអង្គការម៉ារីណុល គាត់អាចយល់អំពីភាសាសញ្ញា។ លើសពីនេះ គាត់បានកំពុងសិក្សាអាជីពពិតប្រាកដមួយ។គាត់ក៏បានបន្តថា : "ឪពុករបស់ខ្ញុំជាកម្មករសំណង់។ ម្តាយខ្ញុំជាកសិករ។ ខ្ញុំសង្ឃឹមថា ខ្ញុំអាចរកប្រាក់បានច្រើនបន្ថែមដើម្បីឧបត្ថម្ភគ្រួសារក្រីក្ររបស់ខ្ញុំ"។

ចំណែកលោកឈុន សារិ ជាយុវជនម្នាក់ទៀតដែលមានអាយុ ២០ឆ្នាំ មានប្រសាសន៍ថា: "ខ្ញុំមិនត្រឹមតែអាចសិក្សាជំនាញ។ ប៉ុន្តែខ្ញុំថែមទាំងអាចស្វែងរកមិត្តថ្មីនៅទីនេះ។ ខ្ញុំធ្លាប់បានធ្វើជាកម្មករសំណង់។ ខ្ញុំបានធ្វើការងារធ្ងន់ធ្ងរដោយទទួលបានប្រាក់តិចតួច។ ខ្ញុំរីករាយនឹងការសិក្សាដើម្បីឱ្យបានក្លាយជាជាងកាត់សក់ម្នាក់។ ខ្ញុំគិតថា ខ្ញុំអាចស្វែងរកប្រាក់កាន់តែច្រើនថែមទៀត ដើម្បីធ្វើការឧបត្ថមគ្រួសាររបស់ខ្ញុំដែរ។

ក្រៅអំពីវគ្គបណ្តុះបណ្តាលនូវជំនាញកាត់សក់អង្គការម៉ារីណុល ក៏មានផ្តល់កម្មវិធីបណ្តុះបណ្តាលជំនាញ រយៈពេលមួយឆ្នាំ សម្រាប់ការសំអាងការកាត់ដេរ ចម្លាក់ស្ពាន់ និងឈើ ការជួសជុលម៉ូតូ និងជំនាញចុងភៅដល់អ្នកថ្លង់ផងដែរ។

MesOctober-2010 OK.qxd 10/4/2010 4:46 PM Page 8





Photo : S. Philong

## ខាន់ ភីរម្យ

### មន្ត្រីកម្ពុជាពិភាក្សាអំពីលទ្ធភាពកសាងផ្លូវដែកមួយខ្សែថ្មី

មន្ត្រីកម្ពុជាកំពុងពិភាក្សាគ្នាលើលទ្ធភាពកសាងបណ្តាញផ្លូវដែកថ្មីមួយខ្សែ ដើម្បីភ្ជាប់ផ្លូវដែកកម្ពុជាទៅនឹងបណ្តាញផ្លូវដែកនៅក្នុងតំបន់។

កិច្ចប្រជុំនេះធ្វើឡើងកាលពីថ្ងៃទី ២១ ខែកញ្ញា នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រោមការដឹកនាំរបស់ឯកឧត្តមគាត ឈន់។

ផ្លូវដែកថ្មីនេះនឹងត្រូវបានសិក្សាលើលទ្ធភាពនៃការកសាងពីប្រជុំជនបាត់ដឹង ខេត្តកំពង់ស្ពឺ ទៅកាន់ស្រុកស្នួល ខេត្តក្រចេះ ដើម្បីតភ្ជាប់ទៅវៀតណាម និងប្រទេសចិន។

សព្វថ្ងៃនេះ បណ្តាញផ្លូវដែកដែលមានស្រាប់នៅកម្ពុជា គឺមានពីរខ្សែ មួយភ្ជាប់ពីភ្នំពេញទៅកាន់ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ និងមួយខ្សែទៀតភ្ជាប់ពីភ្នំពេញទៅកាន់ខេត្តព្រះសីហនុ។ ប៉ុន្តែនៅពេលនេះកំពុងជួសជុលក្រោមហិរញ្ញប្បទានពីធនាគារអភិវឌ្ឍន៍អាស៊ី។

### នាយករដ្ឋមន្ត្រីកម្ពុជា-ថៃ ជួបគ្នានៅប៊ុរីញូវយ៉ក

សម្តេចហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា និងលោកអាប់ភីស៊ីត វ៉ាចាជីវ៉ា នាយករដ្ឋមន្ត្រីថៃ ជួបគ្នានៅប៊ុរីញូវយ៉ក កាលពីថ្ងៃទី២៤ ខែកញ្ញា ក្នុងពេលមេដឹកនាំទាំងពីរបញ្ចប់កិច្ចប្រជុំអាស៊ាន-អាមេរិក។

មេដឹកនាំរដ្ឋាភិបាលទាំងពីរបានឯកភាពគ្នាលើបញ្ហាមួយចំនួន ដូចជាការបញ្ចប់កុំឱ្យមានការប្រើប្រាស់កម្លាំងយោធា ការកាត់បន្ថយទំនាស់នៅតាមព្រំដែន ការលើកកម្ពស់កិច្ចសហប្រតិបត្តិការផ្នែកពាណិជ្ជកម្ម ទេសចរណ៍ និងពិនិត្យមើលលទ្ធភាពនៃការបើកច្រកសម្រាប់ពាណិជ្ជកម្ម និងទេសចរណ៍បន្ថែម។

ក្រៅពីចំណុចទាំងនេះ លោកស្រីថាមរុង្គ រដ្ឋមន្ត្រីអមនាយករដ្ឋមន្ត្រី បានប្រាប់ថា មេដឹកនាំទាំងពីរបានឯកភាពគ្នាឱ្យមានការគ្រប់គ្រងព័ត៌មាន ដើម្បីចៀសវាងការយល់ច្រឡំគ្នាទៅវិញទៅមក និងជំរុញឱ្យមានការផ្លាស់ប្តូរទស្សនកិច្ចថ្នាក់រដ្ឋមន្ត្រីដោយផ្តើមចេញក្រសួងព័ត៌មាននិងអ្នកកាសែត។

### ប្រមុខរដ្ឋពីរប្រទេសបំពេញទស្សនកិច្ចនៅកម្ពុជា

កាលពីដើមខែកញ្ញា កន្លងទៅនេះ ប្រមុខរដ្ឋាភិបាលពីរប្រទេស បានមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា។

លោកអ៊ីវ៉ាន់ ហ្គាស្ប៉ា រ៉ូវិច ប្រធានាធិបតីនៃសាធារណរដ្ឋស្លូវ៉ាគី បានមក ដល់ប្រទេសកម្ពុជា កាលពីថ្ងៃទី៧ ហើយបានបំពេញទស្សនកិច្ចរហូតដល់ទៅថ្ងៃទី៩ ខែកញ្ញា។

លុះដល់ថ្ងៃទី ១៣ កញ្ញា លោកស្រីប្រាទីបា ដេវីស៊ីង ប៉ាទីល ប្រធានាធិបតីឥណ្ឌា និងគណៈប្រតិភូ បានចាប់ផ្តើមដំណើរទស្សនកិច្ច រយៈពេល ៦ថ្ងៃ នៅកម្ពុជាផងដែរ។

គណៈប្រតិភូប្រទេសទាំងពីរទទួលការស្វាគមន៍យ៉ាងកក់ក្តៅពីសម្តេចព្រះបរមនាថនរោត្តម សីហមុនី ព្រះមហាក្សត្រ នៃប្រទេសកម្ពុជា ប្រមុខរដ្ឋាភិបាល និងមន្ត្រីកម្ពុជានានា។

ក្រៅពីពិភាក្សាគ្នាអំពីការពង្រឹងទំនាក់ទំនងការទូត មន្ត្រី និងពាណិជ្ជ-ករ របស់ប្រទេសទាំងពីរ ក៏បានជួបពិភាក្សាគ្នា ជាមួយនឹងពាណិជ្ជករកម្ពុជា ដើម្បីសម្លឹងមើលឱកាស និងសក្តានុពលវិនិយោគ និងពាណិជ្ជកម្មនៅក្នុងប្រទេសកម្ពុជាផងដែរ។

## ប្រទេសសិង្ហបុរី និងម៉ាឡេស៊ី បានព្រមព្រៀងបញ្ចប់ជម្លោះដ៏រ៉ាំរ៉ៃ

ប្រទេសសិង្ហបុរី និងម៉ាឡេស៊ីបានយល់ព្រមបញ្ចប់ជម្លោះមួយដែលមានអាយុកាលរាប់ទសវត្សរ៍ ក្រោយពេលដែលសិង្ហបុរី ប្រកាសឯក-រាជ្យកាលពីខែសីហា ឆ្នាំ១៩៦៥ មកនោះ ។

បណ្តាញព័ត៌មាន ឌីភីអេ បានឱ្យដឹងថា ក្រោយពេលដែលម៉ាឡេស៊ីប្រគល់ឯករាជ្យទៅឱ្យសិង្ហបុរី នៅខែសីហា ឆ្នាំ១៩៦៥ នោះ ម៉ាឡេស៊ីបានរក្សាទុកនូវសិទ្ធិគ្រប់គ្រងចូលទៅកាន់ប្រទេសសិង្ហបុរីរហូតដល់បច្ចុប្បន្ន។ ប៉ុន្តែកាលពីចុងខែកញ្ញាកន្លងទៅនេះ ប្រទេសម៉ាឡេស៊ីបានយល់ព្រមប្រគល់ទៅឱ្យសិង្ហបុរីវិញ។

តាមកិច្ចព្រមព្រៀងសិង្ហបុរី បានយល់ព្រមប្រគល់ដីមួយកន្លែងនៅចំបេះដូងនៃតំបន់ពាណិជ្ជកម្មរបស់ខ្លួនទៅឱ្យម៉ាឡេស៊ីវិញ។

កិច្ចព្រមព្រៀងនេះ គឺជាការសបង្ហាញឱ្យឃើញនូវកិច្ចសហប្រតិបត្តិការថ្មីមួយរបស់ប្រទេសរីកចម្រើនទាំងពីរ នៅក្នុងនាមជាប្រទេសជិតខាងល្អនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។

## ប្រទេសកូរ៉េខាងត្បូងយល់ព្រមផ្តល់ជំនួយអង្ករឱ្យកូរ៉េខាងជើង

អង្ករចំនួន ៥000តោន នឹងត្រូវបានគេដឹកទៅដល់ ប្រទេសកូរ៉េខាងជើង នៅក្នុងខែក្រោយ ដើម្បីជួយសង្គ្រោះដល់ប្រទេសមួយនេះ ក្រោយពេលដែលរងគ្រោះទឹកជំនន់ដ៏ធ្ងន់ធ្ងរ។

បើយោងទៅតាមទីភ្នាក់ងារព័ត៌មានកូរ៉េខាងត្បូងយ៉ុង ហាប់ បានឱ្យដឹងថា មន្ត្រីរដ្ឋាភិបាលកូរ៉េខាងត្បូងនឹងជួបប្រជុំគ្នានៅថ្ងៃអង្គារខាងមុខ ដើម្បីអនុម័តថវិកាមួយ ដែលមានទំហំទឹកប្រាក់ប្រមាណ៧លានដុល្លារ ដើម្បីជួយសង្គ្រោះដល់ប្រទេសដែលឯកានៅក្បែរខាងរបស់ខ្លួននេះ។

ប្រភពដដែលនោះបានឱ្យដឹងថា អំណោយនោះគឺរួមមានដូចជា អង្ករ ៥000តោន ស៊ីម៉ង់១0000តោន និងមីកញ្ចប់ចំនួន ៣លានកេស ក្រៅពីនេះនៅមានថ្នាំពេទ្យ និងឧបករណ៍សង្គ្រោះមួយចំនួនទៀត។ នេះគឺជាកម្មវិធីជំនួយជាថ្មីមួយ ដែលកូរ៉េខាងត្បូងយល់ព្រម ផ្តល់ដល់ប្រទេសកូរ៉េខាងជើង ក្រោយពេលដែលប្រទេសនេះបានចោទប្រកាន់កូរ៉េខាងជើងថា ជាអ្នកបាញ់ពន្លិចនាវាចំបាំងមួយគ្រឿងរបស់ខ្លួន កាលពីប៉ុន្មានខែមុននេះ។

កាលពីដើមខែកញ្ញា កន្លងទៅនេះ ប្រទេសកូរ៉េខាងជើង បានជួបប្រទះនូវ គ្រោះធម្មជាតិដ៏ធ្ងន់ធ្ងរមួយទៀតដែលបណ្តាលពីព្យុះសង្ឃរាមួយ ឈ្មោះកុំបាស៊ូ។




Photo : DR

MesOctober-2010 OK.qxd 10/4/2010 4:46 PM Page 9



# នាយិកាបណ្ណាល័យជាតិ : "ការអានគឺជាវប្បធម៌"

**ខាន់ ភីរម្យ**

*នៅក្នុងចំណោមប្រជាពលរដ្ឋកម្ពុជាជាង ១៤ លាននាក់ កម្ពុជាមានអត្រាអនក្ខរភាព (អ្នកមិនចេះអក្សរដល់ទៅជិត ២លាននាក់។ ដូច្នេះដើម្បីចូលរួមក្នុងការលុបបំបាត់អត្រាអនក្ខរភាពនៅក្នុងប្រទេសលេខនេះ អ្នកនាំសារសូមណែនាំមិត្តអ្នកអានឱ្យជួប ជាមួយនឹងលោកស្រីខ្លួត វិបុលឡា នាយិកាបណ្ណាល័យជាតិដើម្បីឱ្យលោកអ្នកអាចយល់អំពីសារៈសំខាន់នៃអំណាន។*

**អ្នកនាំសារ: តើលោកស្រីនាយិកាយល់យ៉ាងណាដែរអំពីវិស័យអំណាននៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ ?**

**លោកស្រី ខ្លួត វិបុលឡា:** ជាការពិត ខ្ញុំមិនមានតួលេខនូវចំនួនអ្នកអាននៅទូទាំងប្រទេសនោះទេ ។ ប៉ុន្តែឆ្លងតាមរយៈកិច្ចការ និងទំនួលខុសត្រូវរបស់ខ្ញុំជានាយិកាបណ្ណាល័យជាតិ ខ្ញុំគិតយល់ថា វិស័យអំណាននៅក្នុងប្រទេសកម្ពុជានាបច្ចុប្បន្ននេះ មាននូវការរីកចម្រើន ។ ចាប់តាំងពីបណ្ណាល័យជាតិបានបើកដំណើរការឡើងវិញ ក្រោយការដួលរលំរបស់របបប៉ុលពត មកដល់មុនឆ្នាំ២០០៦ ចំនួនអ្នកចូលអានសៀវភៅ ក្នុងមួយឆ្នាំ គឺមានត្រឹមតែពី៥000 ទៅ ៦000នាក់តែប៉ុណ្ណោះ ។ ប៉ុន្តែចាប់តាំងពីឆ្នាំ២០០៦មកដល់ឆ្នាំ២០១០នេះ ក្នុងមួយឆ្នាំ យើងក៏ទទួលប្រមាណពី ៣៥000នាក់ ទៅជិត ៤0000 នាក់ ។ ប៉ុន្តែទោះបីជាវាមានការកើនឡើងក៏ដោយ តែវានៅតែមានចំនួនតិចតួចដែរ ។



Photo : K. Phirum

**បណ្ណាល័យជាតិដែលមានទីតាំងស្ថិតនៅជាប់នឹងសណ្ឋាគារឡឺ រ៉ូយ៉ាល រាជធានីភ្នំពេញ**

**អ្នកនាំសារ : តើនៅកម្ពុជាមានបណ្ណាល័យប៉ុន្មានមកដល់ពេលនេះ?**

**លោកស្រីខ្លួត វិបុលឡា:** មកដល់ឆ្នាំ ២០០៣ នៅកម្ពុជា មានបណ្ណាល័យត្រឹមតែ ៨៩ទេ។ ប៉ុន្តែមកដល់នឹងពេលនេះ គឺមានការកើនឡើងដល់ទៅជាង ១០០ ហើយនៅតាមសាលារៀនវិញ ក្រសួងអប់រំ យុវជន និងកីឡាបានជំរុញឱ្យមានសឹងតែនៅគ្រប់សាលាទាំងអស់ ។ បណ្ណាល័យទាំងអស់នោះដំណើរការឡើងដោយរដ្ឋស្ថាប័នជំនាញ អង្គការក្រៅរដ្ឋាភិបាល និងបណ្ណាល័យនៅតាមសកលវិទ្យាល័យ ។

**អ្នកនាំសារ : តើលោកស្រីយល់ថា អំណានមានសារៈសំខាន់យ៉ាងណា និងជួយអ្វីខ្លះដល់អ្នកអាន?**

**លោកស្រីខ្លួត វិបុលឡា:** ការអានគឺជាសរសរគ្រឹះនៃចំណេះដឹង ហើយវាគឺជាប្រភពនៃជោគជ័យនៅក្នុងជីវិត និងការអភិវឌ្ឍប្រទេស ។ នេះគឺជាសរសរគោលសម្រាប់អភិវឌ្ឍមនុស្សម្នាក់ៗ ។ បើកាលណាយើងអានច្រើន យើងនឹងចេះច្រើន ហើយដឹងអំពីវិធីអភិវឌ្ឍខ្លួនយើងច្រើន ។ បើតាមការស្រាវជ្រាវបានឱ្យឃើញថា ការចំណាយពេល១៥នាទី នៅក្នុងមួយថ្ងៃ នៅក្នុងការអាន អាចជួយឱ្យពួកគេទទួលលទ្ធផលល្អនៅក្នុងការសិក្សា និងការងារ ។

**អ្នកនាំសារ : តើយើងគួរធ្វើយ៉ាងម៉េចដើម្បីបណ្តុះគំនិត និងជំរុញឱ្យកុមារ និងយុវជនកម្ពុជាឱ្យមានការចូលចិត្តវិស័យអំណាន ?**

**លោកស្រី ខ្លួតវិបុលឡា:** មាតាបិតាគឺត្រូវតែបណ្តុះវប្បធម៌នៃការអានតាំងពីកុមារភាព ។ មាតាបិតាត្រូវតែឆ្លៀតពេល និងឧស្សាហ៍អានឱ្យកុមារស្តាប់រាល់ថ្ងៃ នាំកុមារចូលទៅបណ្ណាល័យបណ្ណាគារ ឱ្យបានញឹកញាប់ ។ សម្រាប់អ្នកនៅជនបទ ហើយនិងអាណាព្យាបាលដែលគាត់មិនចេះអក្សរ ក៏ត្រូវតែជំរុញនិងព្យាយាមស្វែងរកសៀវភៅដែលល្អៗ ឱ្យកូនអាន និងព្យាយាមដាស់នូវអារម្មណ៍ពួកគេ ។



Photo : S. Philong

**ការចេះអក្សរគឺជាដំណាក់កាលដ៏សំខាន់នៃការអប់រំ មុននឹងឈានទៅដល់ការចាប់យកនូវការសិក្សាជំនាញឯកទេសនានា។ ដូច្នេះការមិនចេះអក្សរអាចចាត់ទុកជាគ្រោះរាំងស្ទះដល់ការអភិវឌ្ឍ។**

## ប្រវត្តិបណ្ណាល័យជាតិ

លោកស្រីខ្លួត វិបុលឡា នាយកបណ្ណាល័យជាតិកម្ពុជា មានប្រសាសន៍ថា បណ្ណាល័យជាតិនេះ កសាងឡើងតាំងតែពីឆ្នាំ១៩២៤ ហើយបានដំណើរការបម្រើការអានរហូតលើកលែងតែសម័យរបបខ្មែរក្រហមពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។

លោកស្រីបានបន្តទៀតថា ក្រោយពេលរបបខ្មែរក្រហមដួលរលំ បណ្ណាល័យនេះត្រូវបានបើកទ្វារ តែជាមួយនឹងសៀវភៅដែលនៅសេសសល់ត្រឹមតែ ២៣000ក្បាល តែប៉ុណ្ណោះ ដោយភាគច្រើនជាភាសាបារាំង។ ប៉ុន្តែមកដល់ឆ្នាំ២០១០នេះ គឺមានឯកសារ និងសៀវភៅផ្សេងៗ ជាបីភាសា គឺខ្មែរ បារាំង និងអង់គ្លេស លើសពី ១២0000 ក្បាល ហើយនឹងកើនឡើងបន្តៗទៅទៀត។

MesOctober-2010 OK.qxd 10/4/2010 4:46 PM Page 10

## បទយកការណ៍

# ពិភពលោកមានអ្នកអត់ចេះអក្សរ ៧៥៩លាននាក់ នៅ

**ខាន់ ភីរម្យ**

ក្នុងខណៈពេលដែលអ្នកពុំចេះអក្សរ នៅទូទាំងពិភពលោកទាំងមូល ត្រូវបានគេរកឃើញថា មានចំនួនប្រមាណជា ៧៥៩លាននាក់នោះ នៅប្រទេសកម្ពុជា បើតាមមន្ត្រីជំនាញ បានអះអាងថា អ្នកមិនចេះអក្សរ មានប្រមាណជា ២លាននាក់ ។

ដោយយោងតាមតួលេខរបស់នាយកដ្ឋានអប់រំក្រៅប្រព័ន្ធនៃក្រសួងអប់រំ យុវជន និងកីឡា ដែលបានប្រកាសកាលពីពេលថ្មីៗ កន្លងទៅនេះ បានឱ្យដឹងដែរថា ក្នុងចំណោមប្រជាពលរដ្ឋកម្ពុជាជាសរុបប្រមាណជាជាង ១៤លាននាក់នោះ អ្នកដែលមិនចេះអក្សរ ឬអនក្ខរជនត្រូវបានគេរកឃើញថាមាន ២២,៤% ពោលគឺប្រមាណជា ២លាននាក់ ។

ប្រភពដដែលនោះ បានឱ្យដឹងទៀតថា ប្រជាពលរដ្ឋភាគច្រើន ដែលមិនចេះអក្សរភាគច្រើន គឺជាមនុស្សដែលមានវ័យចាស់ ។

តួលេខបានបង្ហាញដែរថា ក្រុមដែលមានមនុស្សអាយុ ចន្លោះពី១៥ ដល់២៤ឆ្នាំ ប្រជាពលរដ្ឋដែលចេះអក្សរនោះមានអត្រាខ្ពស់ ដោយមានប្រមាណជា ៨៧% ខណៈដែលអាយុពី១៥ឆ្នាំ ទៅ ដល់៦០ឆ្នាំវិញនោះ គឺអត្រាចេះអក្សរ គឺមានចំនួន ត្រឹមតែ ៧៧,៦% ប៉ុណ្ណោះ ។



យុវនារីជា ហាន អាយុ ១៧ ឆ្នាំ កម្មការនីរោងចក្រកាត់ដេរ ៦ជាន់ ដែលមកពីស្រុកសណ្ដាន់ ខេត្តកំពង់ធំ ដែលជាមនុស្សម្នាក់នៅក្នុងចំណោមប្រជាពលរដ្ឋកម្ពុជាប្រមាណជា ២លាននាក់នោះ បានឱ្យដឹងថា នាងបានរៀន ត្រឹមតែថ្នាក់ទី២ តែប៉ុណ្ណោះ ដោយកាលនោះ នៅភូមិរបស់នាងគ្មានសាលា ត្រូវដើរឆ្ងាយ ។ ជាមួយនឹងឱកាសដែលរូបនាងបានចូលសាលា ត្រឹមតែ២ឆ្នាំនេះ គឺនាងមិនអាចអានអ្វីបានឡើយ ។ ហានបានបញ្ជាក់ថា: "កុំថាឡើយដល់ទៅអាន សូម្បីតែស្គាល់ ក ខ គ គឺខ្ញុំមិនទាំងស្គាល់ អស់ផងភ្លេចអស់ហើយ" ។ ហានបានរៀបរាប់ទៀតថា នាងបានមកស្វែងរកការងារធ្វើ នៅទីក្រុងភ្នំពេញនេះបាន ២ឆ្នាំហើយ ដោយនាងបានមកជាមួយនិងមិត្តភក្តិនៅក្នុងភូមិ ។ អ្នកដែលបានមកធ្វើការ ជាមួយនិងនាងនោះ ក៏មិនសូវជាចេះអក្សរ ជ្រៅជ្រះដែរ ។ មុនពេលដែលហាន និងមិត្តភក្តិ បានការងារធ្វើនោះ គឺពួកគេបានជួលឱ្យគេ បំពេញប្រវត្តិរូបឱ្យ ហើយពេលសម្ភាសន៍ក៏ជាប់ ហើយក៏ចេះតែធ្វើការបន្តរហូតដល់សព្វថ្ងៃនេះ នៅក្នុងតួនាទីជាអ្នកកាត់ព្រុយ ។ ហានក៏បានបន្តទៀតថា ដោយសារតែភាពមិនចេះអក្សរនេះ នាងជួបការលំបាក ជាពិសេស គឺបាត់ម៉ោងធ្វើការ ដែលនេះគឺជាប្រភពប្រាក់ចំណូលបន្ថែមរបស់ហានជារឿយៗ ។ ហានបន្ថែមដែរថា : "នៅរោងចក្រ គេមានអ្នកកត់ម៉ោងចេញម៉ោងចូល តែខ្ញុំអត់ចេះអក្សរអត់ដឹង គេកត់ស្អី ដល់ពេលបើកលុយ មួយខែៗ ជួនកាល បាត់ម៉ោងថែម ៣ម៉ោង ជួនកាល ៤ម៉ោង ។ ប៉ុន្តែមិនដឹងជាតវ៉ាយ៉ាងម៉េច ? បើខ្ញុំអត់ចេះអាន និងចេះសរសេរអ្វីផងនោះ" ។

ទាំងនេះជាការលំបាករបស់កម្មការិនីរោងចក្រកាត់ដេរដែលកើតឡើងមកពីបញ្ហាមិនចេះអក្សរ ។ ដោយឡែក អ្នកបម្រើ តាមផ្ទះមួយរូបទៀត ដែលមានអាយុ១៩ឆ្នាំ ឈ្មោះថា ស្រី ណាង ដែលមកពីស្រុកសន្ទុក ខេត្តកំពង់ធំដែរនោះ បានឱ្យដឹងថា ផ្ទះដែល នាងស្នាក់នៅ និងធ្វើការសព្វថ្ងៃនេះ គេមានលក់ចាប់ហួយ ហើយនាងតែងគិតលុយគេខុសបាត់លុយ ។ ថៅកែកាត់លុយ និងប្រាក់ខែ សឹងតែរាល់

### អក្ខរភាព គឺជាសិទ្ធិមូលដ្ឋានរបស់ពលរដ្ឋកម្ពុជា

សម្ដេចហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា បានមានប្រសាសន៍ថា អក្ខរភាពគឺជាសិទ្ធិមូលដ្ឋានរបស់ប្រជាពលរដ្ឋកម្ពុជាទាំងអស់គ្នា។

នេះគឺជាសារដែលប្រមុខរដ្ឋាភិបាលកម្ពុជាបានផ្ញើជូនប្រជាពលរដ្ឋកម្ពុជាទាំងអស់ នៅពេលដែលប្រទេសកម្ពុជា រៀបចំទិវាជាតិ និងអន្តរជាតិស្ដីអំពីអក្ខរភាព កាលពីដើមខែ៩ កន្លងទៅថ្មីៗនេះ។ សម្ដេចបានបញ្ជាក់នៅក្នុងសារ នោះដែរថា : "ពលរដ្ឋកម្ពុជាទាំងអស់ គឺមានសិទ្ធិស្មើៗគ្នា នៅក្នុងការទទួលយកនូវការអប់រំ"។

ដើម្បីជំរុញឱ្យផែនការអប់រំសម្រាប់ទាំងអស់គ្នាទទួលបានជោគជ័យនោះ សម្ដេចបានស្នើសុំឱ្យអាជ្ញាធរកម្ពុជាគ្រប់លំដាប់ថ្នាក់ និងដៃគូអភិវឌ្ឍន៍នានា ដោយរួមទាំងសង្គមស៊ីវិលសហការគ្នាដើម្បីជំរុញឱ្យប្រទេសកម្ពុជាឈានទៅលុបបំបាត់ចោលនៅគ្រោះមិនចេះអក្សរ ឬអនក្ខរភាព។

MesOctober-2010 OK.qxd 10/4/2010 4:46 PM Page 11

# នាក់ នៅកម្ពុជាមាន ២លាននាក់



Photo : S. Philong

ខែ។ ណាង និយាយថា នាងមិនមែនមិនចេះអក្សរនោះទេ គឺនាងអាចអាន និងសរសេរបានខ្លះដែរ ជាមួយនឹងចំណេះរៀនដល់ថ្នាក់ទី៥ដែរ។ ប៉ុន្តែចំណេះរបស់នាងត្រឹមប៉ុណ្ណឹង ជួនកាល នាងជួបការលំបាកផងដែរនៅក្នុងពេលដែលនាងធ្វើការនោះ។ ណាងបានបញ្ជាក់ថា: "ជួនកាលគេមកទិញប៊ីយ៉ែផង ទឹកក្រូចផងហើយមានទំសណ្តែកដីច្រើនពេក ឡប់! ខ្ញុំគិតមិនត្រូវបាត់លុយ សងថៅកែ"។

ការរៀបរាប់របស់យុវនារីទាំងពីរនេះ ជាបញ្ហាលំបាកដែលកំពុងកើតមានឡើងនៅក្នុងចំណោមប្រជាពលរដ្ឋកម្ពុជា ដែលមិនមែនមានតែ២នាក់ទេ គឺជាបញ្ហារបស់ប្រជាពលរដ្ឋប្រមាណ ២លាន នាក់ នៅក្នុងនោះក៏មានប្រជាពលរដ្ឋ នៅក្នុងសហគមន៍ជនជាតិភាគតិចផងដែរ។

លោកមៀច មាន អ្នកសម្របសម្រួលនៃអង្គការបណ្តាញការពារទន្លេបី នៅក្នុងភូមិភាគឦសាននៃប្រទេសកម្ពុជា បានមានប្រសាសន៍ថា តាមបទពិសោធន៏ក្នុងការចុះទៅមូលដ្ឋាននៅក្នុងភូមិភាគឦសានសាលារៀនមួយចំនួន គឺនៅតែខ្វះខាតគ្រូ។ ហើយសាលារៀនទៀតសោត គឺនៅឆ្ងាយៗពីភូមិ។ លោកបញ្ជាក់ថា បើប្រៀបធៀបទៅនឹងបណ្តាខេត្តផ្សេងៗនោះ ស្ថានភាពនៃវិស័យអប់រំនៅភូមិភាគឦសាននៃប្រទេសកម្ពុជា នៅមិនទាន់អាចប្រៀបធៀប ឬមួយក៏មានស្ថានភាពប្រសើរជាងនៅខេត្តផ្សេងៗ ទៀតនោះនៅឡើយដែរ។

ចំពោះបញ្ហានេះ លោកតឺរុ ជីន ណៃ ជាតំណាងអង្គការយូណេស្កូប្រចាំកម្ពុជា ក៏បានមានប្រសាសន៏ថា អក្ខរភាព ឬចេះអក្សរជាឫសគល់នៃការអភិវឌ្ឍ។ រីឯអនក្ខរភាពគឺជាឧបសគ្គនៃការអភិវឌ្ឍ។ លោកក៏បញ្ជាក់ឱ្យដឹងដែររថា: "អក្ខរភាពគឺជាការចាប់ផ្តើមនូវថាមពល និងការនាំប្រជាជនចាកចេញពីភាពងងឹត ហើយអក្ខរភាពនឹងជំរុញមនុស្សឆ្ពោះទៅរកពិភពលោកមួយកាន់តែទូលំទូលាយ"។

ដើម្បីជំរុញយុទ្ធនាការលុបបំបាត់ គ្រោះមិនចេះអក្សរចេញពីផ្ទៃប្រទេសនោះ កាលពីពេលថ្មីៗនេះកម្ពុជាក៏បានរៀបចំប្រារព្ធនូវទិវាមួយ ដែលគេហៅថា ទិវាអក្ខរកម្មជាតិ និងអន្តរជាតិក្នុងខេត្តកំពង់ធំ ដើម្បីធ្វើការទាក់ទាញឱ្យមន្ត្រីរដ្ឋាភិបាល ឬអង្គការសង្គមស៊ីវិលព្រមទាំងដៃគូអភិវឌ្ឍន៏នានា ក៏ដូចជាប្រជាពលរដ្ឋទូទៅ ឱ្យមានការខិតខំប្រឹងប្រែងទាំងអស់គ្នាដើម្បីចូលរួមលើកស្ទួយការអភិវឌ្ឍធនធានមនុស្សនៅក្នុងប្រទេសកម្ពុជា។

លោកឈុន ឈន់ ជាអភិបាលខេត្តកំពង់ធំ បានមានប្រសាសន៏ថា នៅក្នុងកិច្ចខិតខំប្រឹងប្រែងមួយដើម្បីលុបបំបាត់នូវគ្រោះមិនចេះអក្សរនេះនៅក្នុងខេត្តកំពង់ធំ អាជ្ញាធរបានកំពុងតែយកចិត្តទុកដាក់ជំរុញ និងលើកកម្ពស់កម្មវិធីអប់រំមួយដែលគេហៅថា កម្មវិធីអប់រំក្រៅប្រព័ន្ធ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ លោកបានស្នើឱ្យមានជាការសហការគ្នាជាប្រព័ន្ធមួយ ដើម្បីឈានទៅរកការសម្រេចឱ្យបាននូវគោលដៅ គឺ ការអប់រំសម្រាប់អ្នកទាំងអស់គ្នា នៅទូទាំងប្រទេស។

ឯកឧត្តមអ៊ឹម សិទ្ធី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានឱ្យដឹងដែរថា ការជំរុញឱ្យកុមារ និងមនុស្សចាស់ទទួលបានការអប់រំ និងរួចផុតពីគ្រោះមិនចេះអក្សរ នៅតែជាបញ្ហានៃបច្ចុប្បន្នភាពដែលទាមទារឱ្យមានការខិតខំយកចិត្តទុកដាក់ជាបន្ថែមទៀត។ ឯកឧត្តមអ៊ឹម សិទ្ធី បានបញ្ជាក់ផងដែរថា: "មនុស្ស មិនចេះអក្សរប្រៀបបាននឹងវត្ថុ ដែលគ្មានព្រលឹង គ្មានពន្លឺ និងជាមនុស្សពិការ ដែលមិនអាចគិតពិចារណារ បានគ្រប់ជ្រុងជ្រោយឡើយ"។ ឯកឧត្តម ក៏បានឱ្យដឹងបន្ថែមថា អក្ខរកម្មគឺជាសិទ្ធិ ជាមូលដ្ឋានរបស់ប្រជាជនគ្រប់រូប។ បើប្រជាជនមិនចេះអក្សរ ការអភិវឌ្ឍប្រទេសជាតិអាចដំណើរការទៅដោយយឺតយ៉ាវណាស់។

តាមតួលេខរបស់នាយកដ្ឋានអប់រំក្រៅប្រព័ន្ធរបស់ក្រសួងអប់រំយុវជន និងកីឡាក៏បានឱ្យដឹងថា កាលពីឆ្នាំសិក្សាកន្លងទៅនេះ មានអនក្ខរជនចំនួន ៥២០៧៨នាក់ បានចូលរៀននៅថ្នាក់អក្ខរកម្ម ទូទាំងប្រទេស ដែលមានចំនួន ២២៦១ថ្នាក់។ ក្នុងនោះ សម្រាប់កម្មវិធីអនក្ខរជន ជាមនុស្សពេញវ័យគិតចាប់ពីអាយុ១៥ឆ្នាំឡើង គេមានកម្មវិធីបណ្តុះបណ្តាលសិស្ស ចំនួន បីកម្រិត គឺការសិក្សា កម្រិតមូលដ្ឋានដោយផ្តើមពីថ្នាក់ក-ខ ឡើងទៅកម្រិតទី២ គឺកម្រិតមធ្យមដោយចាប់ផ្តើម ចំពោះអ្នកបោះបង់ការសិក្សា និងទី៣ គឺកម្រិតស្វ័យសិក្សា ដោយជំរុញការសិក្សាដោយខ្លួនឯង។

## បណ្ណាល័យចល័តអង្គការស៊ីប៉ា

នៅក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីលុបបំបាត់គ្រោះមិនចេះអក្សរនេះ បណ្ណាល័យចល័តកំពុងតែត្រូវបានដំណើរការដោយអង្គការក្រៅរដ្ឋាភិបាលស៊ីប៉ា ដែលជាអង្គការជួយវិស័យអំណាន។

លោកឈឿង ឆេងហាក់ អ្នកសម្របសម្រួលកម្មវិធីអភិវឌ្ឍន៏វិស័យអំណានរបស់អង្គការស៊ីប៉ា បានមានប្រសាសន៏ថា នៅពេលបច្ចុប្បន្ននេះ អង្គការមានសកម្មភាពពីរ គឺបណ្ណាល័យចល័ត និងមណ្ឌលអប់រំសម្រាប់ទាំងអស់គ្នា។ លោកបានឱ្យដឹងថា សម្រាប់បណ្ណាល័យចល័ត អង្គការមាន រថយន្តចំនួន ៧គ្រឿង ដោយនៅក្នុងមួយគ្រឿងមានសៀវភៅ ២០០០ក្បាល និងធ្វើការចល័តទៅតាមគោលដៅចំនួនជាង ៧០កន្លែងនៅជុំវិញរាជធានីភ្នំពេញ។

សម្រាប់កម្មវិធីមណ្ឌលអប់រំទាំងអស់គ្នា គឺអង្គការបានធ្វើសកម្មភាព នៅក្នុងខេត្ត ចំនួន ៥ ដែលកំពង់ចាម កណ្តាល កំពង់ស្ពឺ និងព្រៃវែង ហើយនៅក្នុងខេត្តទាំងអស់នោះ ក៏បានត្រូវបែងចែកជា៤៣មណ្ឌលទៀត ដោយមណ្ឌលនីមួយៗមានម៉ូតូមួយគ្រឿងសម្រាប់ដឹកសៀវភៅប្រមាណជា ២០០ ទៅ៣០០ក្បាល ដើម្បីបម្រើការអានតាមសហគមន៏ដាច់ស្រយាល។

# ព័ត៌មានព្រះសហគមន៍កាតូលិក

## បោះឆ្នោតក្រុមប្រឹក្សាក្រុមសន្ត វ៉ាំងសង់ ដឺ ប៉ូល



Photo : Sokhorn

**សុខន**

ព្រះវិហារសន្តយ៉ូសែប ឬផ្សារតូច នៅរាជធានីភ្នំពេញបានមានការប្រារព្ធកម្មវិធីបោះឆ្នោតជ្រើសរើសរៀបចំក្រុមប្រឹក្សាថ្នាក់ជាតិក្រុមសន្តវ៉ាំងសង់ដឺប៉ូល ។ ពិធីនេះមានអ្នកចូលរួមសរុបប្រហែល៥០នាក់ ដែលមកពីព្រះសហគមន៍កាតូលិកទាំង៣ភូមិភាគនៅទូទាំងប្រទេស កាលពីថ្ងៃទី២៤ កញ្ញា ឆ្នាំ ២០១០ កន្លងទៅ ។

បេក្ខជន៦រូបដែលបានឈរឈ្មោះធ្វើជាតំណាងក្រុមប្រឹក្សាថ្នាក់ជាតិក្រុមសន្ត វ៉ាំងសង់ ដឺ ប៉ូល រួមមាន នៅភូមិភាគភ្នំពេញ គឺលោកផាន គា មកពីមណ្ឌលនិសិត្សកាតូលិកនៅកម្ពុជា និងអ្នកស្រីកែវ វណ្ណារីមកពីព្រះវិហារផ្សារតូច ។ ទីពីរនៅភូមិភាគបាត់ដំបង ដែលរួមមាន លោកធឹម ស៊ីធន់ និងឈួន ប៊ុនហ៊ឹម ដែលមកពីព្រះសហគមន៍ ស្វាយស៊ីសុផុន និង ទី៣ នៅភូមិភាគកំពង់ចាម គឺមានលោកផាន បូរ៉ា ជាប្រធានក្រុមសន្តហ្វ្រង់ស្វ័រនៃក្រុមសន្ត វ៉ាំងសង់ ដឺ ប៉ូល និងលោកជួច ប៊ុណ្ណាត ។

លោកផាន បូរ៉ា ដែលជាប្រធានក្រុមសន្តហ្វ្រង់-ស្វ័រនៃក្រុមសន្តវ៉ាំងសង់ ដឺ ប៉ូល នៃភូមិភាគកំពង់ចាម បានឱ្យដឹងថា ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានេះ ជាយុទសាស្ត្រយ៉ាងល្អក្នុងការពង្រឹងនូវចរន្តការងារទៅថ្ងៃអនាគត ។

លោកតានថូម៉ាសជាជនជាតិសិង្ហបុរី និងជាអ្នកសម្របសម្រួលក្រុមសន្តវ៉ាំងសង់ ដឺ ប៉ូល ប្រចាំនៅតំបន់អាស៊ី និយាយថា : "នេះជាសញ្ញាមួយ ដែលបង្ហាញថាក្រុមសន្តវ៉ាំងសង់ដឺ ប៉ូល នៅក្នុងប្រទេសកម្ពុជាកំពុងតែមានបង្អែករបស់ខ្លួន ពីព្រោះគេអាចដើរដោយខ្លួនឯងក្នុងរយៈ ៦ឆ្នាំ ហើយវាក៏ជាក្តីសង្ឃឹមដែលបង្ហាញថា ក្រុមនេះនឹងអាចរីកឥទ្ធិពលខ្លួនក្នុងការបម្រើបងប្អូនក្រីក្របន្តទៀត ។"

ក្រុមសន្តវ៉ាំងសង់ ដឺ ប៉ូល បានចាប់ផ្តើមប្រតិបត្តិការដំបូង នៅព្រះសហគមន៍ក្នុងប្រទេសកម្ពុជានៅឆ្នាំ២០០៤ ។ សព្វថ្ងៃ ក្រុម នេះមានសកម្មភាពជាច្រើនដូចជា ការចុះសួរសុខទុកអ្នកជំងឺតាមមន្ទីរពេទ្យ ការជួយសិស្សក្រីក្រឱ្យបន្តការសិក្សានិងការជួយជួសជុលផ្ទះជូនអ្នកក្រីក្រ-ល- ។

## កសាងសន្តិភាពតាមរយៈការស្វែងយល់អំពីអន្តរសាសនា

សាសនិកនៃសាសនាធំៗ នៅកម្ពុជាបានចូលរួមសិក្ខាសាលាមួយស្តីអំពី "ការកសាងសន្តិភាពអន្តរ-សាសនា" ដែលត្រូវបានរៀបចំឡើងដោយអង្គការក្រុមការងារដើម្បីដោះស្រាយទំនាស់ ហៅកាត់ថា អេស៊ីធី (ACT) គឺក្នុងគោលដៅដើម្បីឱ្យសាសនានីមួយៗស្វែងយល់ អំពីសាសនានានា និងបញ្ចៀសរាល់ទំនាស់សាសនាក្នុងប្រទេសកម្ពុជា ។

កម្មវិធីនេះបានធ្វើឡើងរយៈពេលបីថ្ងៃ ពីថ្ងៃទី ១៣ ដល់ ១៥ កញ្ញា កន្លងទៅ នៅរាជធានីភ្នំពេញ ដែលមាន គ្រីស្តសាសនិក ឥស្លាមសានិក និងពុទ្ធ-សាសនិកសរុបចំនួន ៣០នាក់ មកពីខេត្តចំនួន ៥ គឺ កំពត កំពង់ចាម បន្ទាយមានជ័យ បាត់ដំបង ព្រមទាំងខេត្ត សៀមរាប ។

លោកធឹម ធន់ ជាគ្រីស្តបរិស័ទកាតូលិក មកពីខេត្តសៀមរាប បានឱ្យដឹងថា សិក្ខាសាលានេះជួយដល់គាត់បានស្វែងយល់ដឹងពីមូលហេតុផ្សេងៗ នៃទំនាស់សាសនា និងផ្លាស់ប្តូរផ្នត់ គំនិតខ្លះដែលយល់ខុសកាលពីពេលមុនចំពោះសាសនាដទៃ ។ លោកធន់បន្តថា : "កាលពីពេលមុន ខ្ញុំយល់ថាពុទ្ធសានិកតែងពួចង់ឱ្យមានសាសនាផ្សេងៗរីកចម្រើន ដូចជាសាសនារបស់ខ្លួនទេ ហើយចំពោះឥស្លាមសាសនិកគឺគេគិតតែអំពីព្រះជាម្ចាស់ខ្លាំងពេក ។ប៉ុន្តែក្រោយពេលបានសិក្សាដឹងអំពីសាសនាទាំងអស់ ខ្ញុំយល់ថាទំនាស់ចេញមកពីបុគ្គល មិនមែនជាសាសនាទេ ។

លោកកែវ វិចិត្រ អ្នកសម្របសម្រួលអង្គសិក្ខាសាលានេះ មានប្រសាសន៍ថា អ្វីដែលសំខាន់ គឺការយល់ដឹងអំពីមូលហេតុផ្សេងៗដែលចេញពីទំនាស់ដើម្បីយើងអាចជៀសវាងទំនាស់នេះបាន ។ លោកវិចិត្របន្ថែមថា ក្នុងរយៈ ពេលនេះ ទាំងព្រះសង្ឃ ឥស្លាមសានិក និងគ្រីស្តបរិស័ទបានស្នាក់រស់នៅជាក្រុមជាមួយគ្នា ដែលពួកគាត់អាចមានឱកាសស្វែងយល់អំពីជំនឿពីគ្នា ទៅវិញទៅមកផងដែរ ។

**កញ្ញា**

## គ្រីស្តបរិស័ទសិក្សាអំពីទេវវិទ្យានៃរាង្គកាយមនុស្ស



Photo : Sokhorn

បងស្រី ប៉ោឡា ប្រធានគណៈកម្មការ សង្គហៈព្រះសហគមន៍ភូមិភាគភ្នំពេញ ផ្នែកសុខភាព បាននិយាយថា ការគោរពឱ្យតម្លៃលើរូបរាងកាយបុរសនិងស្ត្រីគឺសំខាន់សម្រាប់សញ្ញានៃក្តីស្រលាញ់ ។

កាលពីថ្ងៃទី១០-១២ ខែកញ្ញានេះ គណៈកម្ម-ការក្រុម សង្គហៈ ភូមិភាគភ្នំពេញ មានរៀបចំអង្គសិក្ខាសាលាស្តីអំពីបញ្ហាសុខមាភាពលើការលើកកម្ពស់តម្លៃជីវិត" នៅព្រះវិហារសន្តយ៉ូសែប រាជ-ធានីភ្នំពេញដែលមានប្រធានបទ "ទេវវិទ្យានៃរាង្គកាយមនុស្ស" ។ សិក្ខាសាលានេះមានទិសដៅឱ្យគូស្វាមីជ្រើសរើសការពន្យាកំនើតតាមលក្ខណៈធម្ម-ជាតិ និងជៀសវាងឱ្យបាននូវការរំលូតកូន ។

កម្មវិធីក៏បានការចូលរួមពីតំណាងក្រុមសង្គហៈទាំងបីភូមិភាគកាតូលិក លោកវេជ្ជបណ្ឌិតសិង្ហបុរី ព្រមទាំងភ្ញៀវកិត្តិយសមួយចំនួនទៀត ។

បងស្រី ប៉ោឡា បានមានប្រសាសន៍ថា: "យើងបង្ហាញឱ្យបងប្អូនយល់អំពីការសម្រេចចិត្តក្នុងការមានកូន ដែលនេះគឺអាចចាត់ទុកជាព្រះអំណោយទានដ៏វិសេសមកពីព្រះជាម្ចាស់" ។

យុវជនឃឹម រិទ្ធី ពីព្រះសហគមន៍ជុំគីរីនិយាយថា លោកបានស្គាល់អំពីអត្ថន័យ និងតម្លៃនៃទំនាក់ទំនងប្តីប្រពន្ធដោយពួកគេត្រូវមានភាពទទួលខុសត្រូវទាំងសងខាងទាំងទង្វើ និងចិត្តកាយ ។

**សុខន**

MesOctober-2010 OK.qxd 10/4/2010 4:47 PM Page 13

# ព័ត៌មានព្រះសហគមន៍កាតូលិក

## សម្តេចប៉ាបតែងតាំងលោកអភិបាលជីអូ វ៉ាន់នី អាល់នីឡូ ជាអគ្គរាជទូតប្រចាំនៅប្រទេសថៃ និងនៅប្រទេសកម្ពុជា



Photo : DR

កាលពីថ្ងៃទី២៤ កញ្ញា កន្លងទៅនេះសម្តេចប៉ាបបេណេឌិកទី១៦ បានតែងតាំងលោកអភិបាលជីអូវ៉ាន់នី អាល់នីឡូ ជាអគ្គរាជទូតប្រចាំនៅព្រះរាជាណាចក្រថៃ និងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងជាអ្នកសម្របសម្រួលកិច្ចការនៅព្រះសហគមន៍ ប្រទេសមីយ៉ាន់ម៉ា និងនៅប្រទេសឡាវ ។ អ្វីគឺជាការកត់សម្គាល់ដ៏សំខាន់នោះគឺលោកអភិបាលជីអូ វ៉ាន់នី អាល់នីឡូត្រូវបានតែងតាំង ជាអគ្គរាជទូតសម្តេចប៉ាប ប្រចាំនៅសាធារណរដ្ឋប្រជាធិតេយ្យកុងហ្គោ តាំងពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០១ ។

លោកអភិបាល ជីអូ វ៉ាន់នី អាល់នីឡូ កើតនៅថ្ងៃទី៥ មករា ឆ្នាំ១៩៥៥ ក្នុងតំបន់អាវ៉ាសាទីក្រុងកាស់សីតា ប្រទេសអ៊ីតាលី ហើយលោកបានទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យ នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៧៨ នៅព្រះសហគមន៍កាតូលិក ភូមិភាគអាវ៉ាសា ។ លោកអភិបាលបានចូលបម្រើការងារក្នុងវិស័យការទូតនៅថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៨៣ បន្ទាប់ពីលោកបានទទួលការអប់រំផ្នែកកិច្ចការការទូត នៅក្នុងទីក្រុងរ៉ូម ដោយលោកទទួលបានសញ្ញាបត្រនៅថ្នាក់អនុបណ្ឌិតការទូតផ្នែកវិទ្យាសាស្ត្រនៅសាលាច្បាប់ខេនុន ។ លោកអភិបាលក៏បានបំពេញការងារជាអគ្គរាជទូត ដោយជោគជ័យក្នុងប្រទេស ប៊ូរុនឌី ថៃឡឺបង់ និងប្រទេសប្រេស៊ីល ។

លោកអភិបាលជីអូ វ៉ាន់នី អានីឡូ នឹងស្នាក់នៅក្នុងទីក្រុងបាងកក ប្រទេសថៃ ហើយលោកនឹងចុះទៅតាមប្រទេសផ្សេងៗ យ៉ាងទៀងទាត់នៅពេលដែលមានសេចក្តីត្រូវការចាំបាច់ ឬមានពិធីបុណ្យសំខាន់ៗ នៅតាមព្រះសហគន៍កាតូលិកនៅក្នុងប្រទេសនីមួយៗ ។

លោកអភិបាលជាអ្នកតំណាងសម្តេចប៉ាប ។ លោកអភិបាល មានកិច្ចការទូតជាមួយប្រទេសដទៃ និងក៏មានទំនាក់ទំនងជាផ្លូវការជាមួយរាជរដ្ឋាភិបាលកម្ពុជាផងដែរ ។ យើងក៏អាចនិយាយថា លោកអភិបាលជាឯកអគ្គរាជទូតនៃសម្តេចប៉ាបដែលជាអ្នកទទួលសិទ្ធិពីសម្តេចប៉ាបតំណាងនៅ ក្នុងប្រទេសនីមួយៗ ដែលមានទំនាក់ទំនងការទូតជាមួយសម្តេចប៉ាប ។

សូមបញ្ជាក់ដែរថាបច្ចុប្បន្ននេះមានស្ថានទូតចំនួន៨០ នៅទីក្រុងរ៉ូម មានទំនាក់ទំនងការទូតជាមួយនិងសម្តេចប៉ាប ។ សម្តេចប៉ាបក៏បានភ្ជាប់ទំនាក់ទំនងការទូតជាមួយប្រទេសកម្ពុជាតាំងពីថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៤ ។

លោកជីអូ វ៉ាន់នី អានីឡូ និយាយ៤ភាសា គឺ អង់គ្លេស បារាំង អេស្ប៉ាញ និងព័រទុយហ្គាល់ ។

## នឹកគុណដល់បុព្វការីជន និងសន្តបុគ្គលនៅរដូវភ្ជុំ



Photo : Nith

នៅឱកាសបុណ្យភ្ជុំនេះ ព្រះវិហារសន្តយ៉ូសែប បានរៀបចំកម្មវិធីចែកអំណោយដល់គ្រួសារដែលមានជីវភាពខ្វះខាត ចំនួន១០០គ្រួសារ ដែលមកពីទីតាំងផ្សេងៗគ្នានៅរាជធានីភ្នំពេញ ក្នុងនោះមានទាំងគ្រីស្តបរិស័ទ និងទាំងពុទ្ធបរិស័ទ ។ កម្មវិធីនេះប្រព្រឹត្តិទៅនៅថ្ងៃ៣០ ខែកញ្ញា ដែលរៀបចំឡើងដោយក្រុមសង្គហៈ ។

តាមប្រសាសន៍លោកអ៊ឹង ទ្រី អនុប្រធានកម្មការសង្គហៈព្រះសហគមន៍សន្តយ៉ូសែប បានឱ្យដឹងថា : "យើងចង់គោរពចំពោះបុព្វការីជន ដែលបានចែកឋានទៅ ។ ចំពោះយើងជាគ្រីស្តបរិស័ទបងប្អូនទាំងនោះប្រៀបដូចសន្តបុគ្គលដែលយើងគួរគោរព និងរំលឹកដល់គុណរបស់គាត់ ។" លោកអ៊ឹង ទ្រី បន្តថា យើងក៏អាចនិយាយបានថា ការដឹកនាំជំនឿខ្លួន និងការដើរ តាមមាគ៌ាព្រះជាម្ចាស់ គឺត្រូវស្រលាញ់អ្នកដទៃឱ្យដូចជាខ្លួនឯង ហើយយល់អំពីទុក្ខលំបាករបស់បងប្អូនដែលនៅជុំវិញខ្លួន ។

លោកសៅ សិន មានវ័យ៥៣ឆ្នាំ និងជាអ្នករត់ម៉ូតូឌុបនៅគីឡូលេខ៦ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ បាននិយាយដែរថា: "ខ្ញុំសប្បាយចិត្តដែលមកទទួលអំណោយនេះ ។ នេះជាលើកទី២ សម្រាប់ខ្ញុំ តែមិនមានន័យថា ខ្ញុំ និងគ្រួសារ មិនខិតខំប្រឹងរកចំណូលដោយដេកចាំតែសំណាងនោះឡើយ ។"

សកម្មភាពនេះចែកអំណោយនេះ គឺតែងតែធ្វើឡើងនៅក្នុងរដូវបុណ្យភ្ជុំ និងបុណ្យចូលឆ្នាំប្រពៃណីខ្មែរ ។ អំណោយដែលគេអាចចែកជូន គឺមានដូចជាអង្ករ ទឹកត្រី ត្រីខកំប៉ុង សម្លៀកបំពាក់ ហើយសម្ភារៈ ដែលថវិកាជាវិភាគទានរបស់គ្រីស្តបរិស័ទដែលបានមកចូលរួមអភិបូជារាល់ថ្ងៃអាទិត្យ ។

**សុខន**

## ការយកចិត្តទុកដាក់ចំពោះគ្នា ក្នុងនាមបុត្រធីតាព្រះជាម្ចាស់

បងប្អូនគ្រីស្តបរិស័ទនៅព្រះសហគមន៍កាកាតូលិកកំពង់សោម បានរួបរួមគ្នាធ្វើការផ្តល់អំណោយឱ្យដល់បងប្អូនដែលមានជីវភាពខ្វះខាត ចំនួន ៥០គ្រួសារ ។ កម្មវិធីនេះត្រូវបានប្រព្រឹត្តិទៅ កាលពីថ្ងៃទី៧ ខែកញ្ញា និងមានការជួសជុលផ្ទះមួយខ្នងដល់បងប្អូនដែលរស់នៅសង្កាត់ក្បាលជ្រូកផងដែរ ។

បងស្រីស្លាវ៉េ នៃក្រុមបងស្រី ដូមីនិក អ្នកសម្របសម្រួលកម្មវិធីនេះ និយាយថា : "មិនថា យើងមានជំនឿផ្សេងគ្នា តែយើងមានចិត្តមេត្តា និងក្តីស្រលាញ់សម្រាប់គ្នា ។"

អំណោយទាំងនោះ រួមមានអង្ករ ១០គីឡូក្រាម សម្លៀកបំពាក់ ស្បែកជើង ប្រេងកូឡាក្រមា និងចែកជូនឱ្យដល់បងប្អូនដែលរស់នៅក្នុងសង្កាត់បឹងតាព្រហ្ម កោះខ្យង ស្រែអំបិល ព្រែងត្រយឹង ស្រែចាំលើ និងចាំក្រោម កំពង់សោម និងសង្កាត់ក្បាលជ្រូកផងដែរ ។

**សុខន**

MesOctober-2010 OK.qxd 10/4/2010 4:47 PM Page 14



# ស៊ីអេសស៊ីបង្ហាញ សក្ខីភាពនៃអ្នកម្ដាយតេរេសាលើផ្ទាំងសំពតស

**ជាត សំភី**

ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក ឬស៊ីអេសស៊ី កាលពីពេលថ្មីនេះបានរៀបចំ មហោស្រពភាពយន្តអន្តរជាតិ ២០១០ នៃអ្នកម្ដាយតេរេសា។ មហោស្រពត្រូវបានប្រារព្ធធ្វើឡើងនៅឯរោងភាពយន្តនៃផ្សារទំនើបសូរិយារាជធានីភ្នំពេញនៅពីថ្ងៃទី១០ដល់ទី១២ កញ្ញា និងនៅសៀមរាប នៅថ្ងៃទី១៤ ខែកញ្ញានៅរោងភាពយន្ត បារយណ៍អណ្តែត។ មហោស្រពនេះធ្វើឡើង ក្នុងគោលបំណងរំឭកខួបមួយសតវត្សរ៍នៃអ្នកម្ដាយតេរេសាដ៏មានសុភមង្គលនៃទីក្រុងកាល់គូតាប្រទេសឥណ្ឌា និងបង្ហាញនូវបេសកកម្ម នៃក្រុមបងស្រីមេត្តាករុណា ដែលមានការបម្រើដ៏អស្ចារ្យសម្រាប់អ្នកក្រីក្រ។

មហោស្រពភាពយន្តអ្នកម្ដាយតេរេសា នៅឆ្នាំ២០១០នេះ គឺត្រូវបានបញ្ចាំងជាភាពយន្តឯកសារ និងប្រមូលផ្តុំនូវការចងចាំអំពីបេសកកម្មសប្បុរសធមិរបស់មនុស្សជាតិ។ នេះគឺជាកេរ្តិ៍ដំណែលនៃគំរូសប្បុរសធមិ កាលពីអតីតកាល ឆ្លោះមកបច្ចុប្បន្នកាល និងទៅអនាគតកាល។

លោកលី សុវណ្ណា នាយកនៃការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិកបានមានប្រសាសន៍នៅទិវាបើកកម្មវិធីមហោស្រពកាលពីថ្ងៃទី១០ កញ្ញា ថា: "មហោស្រពមានគោលបំណងទី១ ដើម្បីរំឭកខួបកំណើតទី១00ឆ្នាំ នៃអ្នកម្ដាយតេរេសា និងទីពីរបង្ហាញអំពីសក្ខីភាពនៃសេចក្ដីស្រឡាញ់ និងសប្បុរសធមិរបស់អ្នកម្ដាយ"។

លោក គីកេ ហ្វិការេដូ អភិបាលព្រះសហគមន៍ភូមិភាគបាត់ដំបង ដែលធ្វើជាអធិបតីនៅក្នុងកម្មវិធីបើកមហោស្រព មានប្រសាសន៍ថា: "មហោស្រពខ្សែភាពយន្តនេះបានផ្ដល់ការយល់ដឹងអំពីអ្នកម្ដាយតេរេសាទៅកាន់សាធារណជន"។ លោកបានបន្តថា ការបញ្ចាំងខ្សែភាពយន្ត គឺជាមធ្យោបាយដ៏មានអនុភាពមួយ ដើម្បីឱ្យទាំងគ្រីស្ដបរិស័ទកាតូលិក និងសាធាណជនទូទៅធ្វើការពិចារណា អំពីជីវិតជាគ្រីស្ដបរិស័ទ និងការបម្រើអ្នកក្រីក្រ។

មនុស្សប្រមាណ ៤00នាក់ បានចូលរួមទស្សនាការបញ្ចាំងខ្សែភាពយន្តដំបូង នាថ្ងៃទី១០ ខែកញ្ញា នៅផ្សារទំនើបសូរិយានៅរាជធានីភ្នំពេញ។

លោកស៊ិន សុភា ជាគ្រីស្ដបរិស័ទនៃព្រះសហគមន៍កាតូលិកចំការឡៀងខេត្តតាកែវ និយាយថា: "លោកបូជាចារ្យបានប្រាប់ខ្ញុំអំពីការលះបង់របស់អ្នកម្ដាយតេរេសាចំពោះការបម្រើអ្នកក្រីក្រ។ អ្នកម្ដាយ ក៏បានព្យាយាមប្រឈមមុខនឹងឧបសគ្គនានាដើម្បីជួយពួកគេ ដោយជឿជាក់លើព្រះជាម្ចាស់ជានិច្ច"។លោកបានបន្តថា ខ្សែភាពយន្តបាននាំមកឱ្យលោកនូវបទពិសោធន៍ល្អក្នុងការបម្រើអ្នកដទៃ ជាពិសេសអ្នក ក្រីក្រ ។

កញ្ញាស៊ិន សៀងអៃ ជាទស្សនិកជន និងជាពុទ្ធបរិស័ទរស់នៅភ្នំពេញ បាននិយាយផងដែរថា: "ខ្ញុំធ្លាប់បានអានអំពីប្រវត្តិរបស់អ្នកម្ដាយតេរេសានិងទង្វើសប្បុរសធមិរបស់គាត់។ តែឥឡូវនេះ ខ្ញុំអាចឃើញនូវទង្វើសប្បុរសធមិនេះនៅលើខ្សែភាពយន្តហើយ។ ទោះបីខ្ញុំគឺជាពុទ្ធបរិស័ទមែន ប៉ុន្តែខ្ញុំយល់ឃើញថា សាសនាគ្រីស្ដគឺបាននាំមកនូវក្ដីស្រឡាញ់ និងអំពើអហិង្សា។

ទស្សនិកជនជាពុទ្ធបរិស័ទមួយរូបទៀត ក៏បាននិយាយដែរថា: "ខ្ញុំកោតសរសើរដល់វីរភាពរបស់អ្នកម្ដាយតេរេសាដែលជួយអ្នកក្រីក្រ។ អ្នកម្ដាយគឺហ៊ានតវ៉ាជាមួយនិងអាជ្ញាធរឥណ្ឌាដើម្បីការពារអ្នកក្រីក្រ"។ លោកបន្តថា: "បន្ទាប់ពីទស្សនាចប់ ខ្ញុំគិតយល់ថាកិច្ចការមនុស្សធមិមិនមានព្រំដែនទេ។ មនុស្សម្នាក់ៗអាចជួយគ្នាទៅវិញទៅមកទោះបីជាសាសនាណាក៏ដោយ គឺដូចដែលដូនជីកាតូលិកជួយបុរសដែលកាន់សាសនាហិណ្ឌូ ដែលរូបគាត់មានជំងឺ និងបាត់បង់អស់នូវក្ដីសង្ឃឹមនោះ"។



Photo : Nith

## ជីវិតខ្ញុំ

# អ្វីដែលយើងគួរធ្វើ គឺកិច្ចការដ៏សាមញ្ញក្នុងការបម្រើបងប្អូន

**អ៊ឹម សុខន**



Photo : Nith

លោកបូជាចារ្យ បប់ ពិសេ: "សម្រាប់ កិច្ចការដ៏តូចប្រចាំថ្ងៃ ដែលយើងធ្វើទៅមិនសូវមានគេចាប់អារម្មណ៍ ប៉ុន្តែនេះមិនបានន័យថាកិច្ចការនោះគ្មានតម្លៃ និងទទួលបរាជ័យឡើយ ។"

លោកបូជាចារ្យបប់ ពិសេ គឺជាជនជាតិកាណាដា ។ លោកបូជាចារ្យបានទទួលអគ្គសញ្ញាបូជាចារ្យតាំងពីឆ្នាំ១៩៦៩ មកម្ល៉េះ ។

លោក មានប្រសាសន៍ថា អ្វីដែលរឹតតែល្អនោះគឺយើងធ្វើជាមនុស្សព្យាយាម និងរស់នៅក្នុងជំនឿពិតប្រាកដដោយការទុកចិត្តលើព្រះជាម្ចាស់ ។ ព្រះអង្គទ្រង់នឹងប្រទានឱ្យតាមអ្វីដែលយើងទូលអង្វរព្រះអង្គ ដោយធ្វើការអធិដ្ឋានសម្រាប់គ្រប់កិច្ចការដែលយើងកំពុងធ្វើ និងនឹងធ្វើ ។ ការរៀនបួស និងការសម្រេចចិត្តដើរតាមមាគ៌ាព្រះយេស៊ូ ជាអ្វីមួយនិងនាំឱ្យយើងយល់ពីខ្លឹមសារនៃសេចក្តីស្រលាញ់ ។ ហេតុនេះលោកមិនបានទទួលការរារាំងខណ្ឌចែកពីសំណាក់អាណាព្យាបាល ក្នុងការសម្រេចចិត្តធ្វើជាអ្នកបួសនោះឡើយ ។ លោកបន្តថា: "ការអានព្រះបន្ទូលជាតំណាងនៃសេចក្តីស្រលាញ់ និងការគោរពដែលជួយតម្រង់យើងឱ្យយល់ច្បាស់អំពីអ្វីដែលជាការត្រាស់ហៅរបស់ព្រះយេស៊ូ" ។

នៅឆ្នាំ១៩៩៧ ខែធ្នូ លោកបានចូលមកបម្រើព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជា ។ លោកទទួលការខុសត្រូវដំបូងនោះ គឺនៅឆ្នាំ២000 នៅព្រះវិហារសន្តយ៉ូសែប រាជធានីភ្នំពេញ ។

លោកបានពន្យល់បន្ថែមអំពីដំណើរជីវិតមុននឹងរូបលោកក្លាយ ជាបូជាចារ្យមួយរូប យ៉ាងដូច្នេះថា លោកគឺជាបុគ្គលម្នាក់ ដែលចូលចិត្តស្វែងយល់អំពីវប្បធម៌ផ្សេងៗគ្នា។ ហេតុនេះលោកបានស្ម័គ្រចិត្តធ្វើការងារនៅក្នុងព្រះសហគមន៍កាតូលិក ប្រទេសកាណាដា ក៏ដូចជានៅរាល់បណ្តាប្រទេសមួយចំនួនទៀត មាន ហ្វីលីពីនជាដើម ។

លោកបាននិយាយថា: "ការពិត! ការស្ញឹងស្ញាធិ៍និងរិះគិតអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងជួយឱ្យយើងកាន់តែយល់ច្បាស់អំពីជីវិត ដែលព្រះអង្គបានរៀបចំទុកសម្រាប់យើងម្នាក់ៗ" ។ លោកបូជាចារ្យរូបនេះមានប្រសាសន៍ទៀតថា ចំពោះកិច្ចការប្រចាំថ្ងៃដ៏សាមញ្ញគឺជាការបម្រើបងប្អូន ហើយបើយើងអាចជួយគេ គេនឹងសប្បាយចិត្តនោះ គឺយើងផ្ទាល់ក៏គួរសប្បាយ ពីព្រោះអ្វីដែលយើងធ្វើ គឺបានបង្ហាញអំពីការយល់ទុក្ខធុរៈគ្នាចំពោះគ្នា ។

លោកថាដូច្នេះ អ្វីរឹតតែល្អប្រសើរទៀតនោះ គឺយើងត្រូវឱ្យព្រលឹងរូបកាយ និងចិត្តរបស់យើងរស់នៅស្របគ្នា ហើយកិច្ចការទាំងនេះ យើងក៏អាចធ្វើទៅបានដោយការស្តាប់សូរសៀងព្រះអង្គ ។

លោកបូជាចារ្យបប់ នឹងនឹងទទួលមុខងាររបស់លោក ធ្វើជាប្រធានទេវវិទ្យាល័យ នៃសន្តយ៉ូហានម៉ារី វិយ៉ាណេបន្ទាប់បន្តពីលោកបូជាចារ្យប្រ៊ុយណូសម្រាប់ការងាររយៈពេល៦ឆ្នាំ ។

## ប្រតិទិនអភិបូជា

- **ភាសាខ្មែរ** : ព្រះវិហារសន្តយ៉ូសែបភ្នំពេញ (០១២ ៧៨២ ២៤១) ថ្ងៃច័ន្ទ-សៅរ៍ : ព្រឹកម៉ោង៦។ ថ្ងៃអាទិត្យ : ម៉ោង ៨ព្រឹក និងម៉ោង៤រសៀល។
  -កំពង់សោម (០១៦ ៨៤០ ៥៤០) ថ្ងៃច័ន្ទ ថ្ងៃពុធ និងថ្ងៃសុក្រ : ល្ងាចម៉ោង៥។ ថ្ងៃអង្គារ ថ្ងៃព្រហស្បតិ៍ និងថ្ងៃសៅរ៍ : ព្រឹកម៉ោង៦។ ថ្ងៃអាទិត្យ : ម៉ោង ៨ព្រឹក។
  -សៀមរាប (០៦៣ ៩៦៥ ២៨០) ថ្ងៃអាទិត្យ : ម៉ោង៧:៣០ព្រឹក។ ថ្ងៃច័ន្ទ-ថ្ងៃព្រហស្បតិ៍ : ព្រឹក ៦:៣០ម៉ោង។ ថ្ងៃសុក្រ : ម៉ោង ៦:៣០ល្ងាច។
  -បាត់ដំបង (ពេទ្យយាយជី) ថ្ងៃអាទិត្យ : ម៉ោង ៨:០០ព្រឹក។ ថ្ងៃច័ន្ទ : ល្ងាច៦:០០។ ថ្ងៃអង្គារ-សុក្រ : ម៉ោង៦:១៥ ព្រឹក។
- **Français** : 1er et 3ème Samedi du mois à 5:30pm ; 2ème et 4ème Dimanche du mois à 11:00am; à l'église de St. Joseph, #1788B, RN5, PP.
- **English** : - Phnom Penh : Sunday at 10: 00 am; at St. Joseph Church (#1788B, NR5, PP); Saturday at 5: 00 pm, at World Vision Cambodia (#2 St 71, PP); - Sihaknouk Ville : Sunday at 5:00 pm; # Catholic Church St.12 13 Mattapheap; H/P: 016 840 540 (Fr. Werachai); - Siem Reap : Saturday at 6:30 pm; #Catholic Church, No 027 East River Side Street. - Battambang : Saturday: at 6:00 pm at Battamabang Church (Pet Yeaychi), Rumchek 1, Rattanak, H/P: 012 911 147 (Fr. Totet).

MesOctober-2010 OK.qxd 10/4/2010 4:47 PM Page 16



# ទីម័រខាងកើត និងការតស៊ូដើម្បីឯករាជ្យភាព

**ជាត សំភី**



## ទីម័រខាងកើត

ទីម័រខាងកើតស្ថិតនៅពាក់កណ្តាលលើកោះទីម័រ ហើយគ្រប់គ្រងផ្ទៃដីប្រមាណជា ១៥០០០គម$^{2}$។ ប្រទេសនេះមានអាកាសធាតុត្រូពិច ដែលបែងចែកជារដូវប្រាំង និងរដូវវស្សា។

ឌីលីជារាជធានីរបស់ប្រទេស គឺជាទីក្រុងធំបំផុតរបស់ប្រទេស ហើយក៏ជាទីក្រុងកំពង់ផែផងដែរ។ ទីក្រុងលំដាប់ទីពីរគឺបូកូ នៅភាគខាងកើតនៃកោះ។ ឌីលីមានអាកាសយានដ្ឋានដែលជាអាកាសយានដ្ឋានតែមួយគត់នៅទីម័រខាងកើត។ ៧០% នៃការងារ គឺស្ថិតនៅក្នុងវិស័យកសិកម្មដែលផ្តល់ ៤៣% នៃថវិការជាតិ។ ឧស្សាហកម្មមានការអភិវឌ្ឍទន់ខ្សោយ (តម្បាញ ការធ្វើដំណាំកាហ្វេ) ដែលប្រើប្រាស់តែ ៥% នៃកម្លាំងពលកម្ម ស្មើនិង ១៧% នៃចំនួនប្រជាជន។ នេះគឺជាប្រទេសដែលមានកាតូលិកសាសនិកភាគច្រើន ៨០%នៃចំនួនប្រជាជន។

ទីម័រខាងកើតជាប្រទេសថ្មីនៃអាស៊ីអាគ្នេយ៍។ ប្រទេសនេះគ្របដណ្តប់លើពាក់កណ្តាល ផ្នែកខាងកើតនៃកោះទីម័រ ដែលជាប់នឹងផ្នែកនៃកោះ ទីម័រខាងលិចដែលស្ថិតនៅក្នុងអធិបតេយ្យភាពរបស់ឥណ្ឌូនេស៊ី។ ទីម័រមានប្រភពចេញអំពីអាណានិគមព័រទុយហ្គាល់។ នៅឆ្នាំ១៨៥៩ សន្ធិសញ្ញាមួយត្រូវបានចុះហត្ថលេខាដោយ តាមរយៈនេះប្រទេសព័រទុយហ្គាលប្រគល់ជាផ្លូវការផ្នែកខាងលិច នៃកោះឱ្យទៅឱ្យហូឡង់ ដែលពីកាលនោះ ធ្វើអាណានិគមនៅលើប្រទេសឥណ្ឌូនេស៊ី។ តែទីម័រខាងកើតស្ថិតនៅក្រោមអាណានិគមរបស់ព័រទុយហ្គាលរហូតដល់ការលុកលុយរបស់ឥណ្ឌូនេស៊ីនៅឆ្នាំ១៩៧៥។

នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ដោយទាញចំណេញពីចលនាមានប្រភពពីបដិវត្តផ្លាស់ប្តូររបបនៅប្រទេសព័រទុយហ្គាល រណសិរ្សបដិវត្តន៍ដើម្បីឯករាជ្យភាពទីម័រខាងកើត បានប្រកាសឯករាជ្យភាពនៃទីម័រខាងកើត។ បានរយៈពេល ៩ថ្ងៃ ទីម័រខាងកើតត្រូវបានកងទ័ពឥណ្ឌូនេស៊ីចូលកាន់កាប់។ ពេលនោះកងទ័ពបាញ់ប្លោងដាក់ភូមិនានានៅទីម័រខាងកើត ដែលត្រូវសង្ស័យថា ផ្តល់ជំនួយដល់ក្រុមឧទ្ទាមរណសិរ្សដើម្បីឯករាជ្យទីម័រខាងកើត។

**ការប្រយុទ្ធដើម្បីឯករាជ្យភាព**

ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៩១ កងទ័ពឥណ្ឌូនេស៊ី បានបាញ់ទៅលើហ្វូងមនុស្ស ដែលកំពុងតែកាន់ទុក្ខ បន្ទាប់ពីការស្លាប់របស់និស្សិតម្នាក់ នៅផ្នូរកប់ខ្មោចសានតាគ្រូស នៅឯរដ្ឋធានីឌីលី។ មានមនុស្សប្រមាណ ២០០នាក់ ត្រូវបានសម្លាប់នៅថ្ងៃនោះ។ បាតុករផ្សេងទៀត ត្រូវបានគេធ្វើឃាត នៅថ្ងៃបន្តបន្ទាប់មក ក្រោយពីការស្វែងរករបស់យោធា។

បុព្វហេតុរបស់កោះទីម័រខាងកើតដើម្បីឯករាជ្យភាពបានជះឥទ្ធិពលទៅលើប្រព័ន្ធផ្សព្វផ្សាយរបស់អន្តរជាតិ។ នាខែមិថុនា ឆ្នាំ១៩៩៧ ប្រធានាធិបតីអាហ្រ្វិកខាងត្បូង Nelson Mandela បានមកជួបមេដឹកនាំរណសិរ្សដើម្បីឯករាជ្យភាពនៃកោះទីម័រខាងកើត សានានា ហ្គូស្មាវ ដែលនាខណៈនោះត្រូវបានជាប់ឃុំឃាំង។ ដំណើរទស្សនកិច្ចនេះ គឺបង្កើនសំពាធទៅលើរដ្ឋាភិបាលឥណ្ឌូនេស៊ីដើម្បីឈានទៅរកដំណោះស្រាយនៃការចរចា។

បន្ទាប់មកនៅឆ្នាំ១៩៩៧ វិបត្តិសេដ្ឋកិច្ចអាស៊ីក៏បានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរចំពោះប្រទេសឥណ្ឌូនេស៊ី។ របបយោធារបស់ លោកស៊ូហាតូជួបប្រទះជាបន្តបន្ទាប់នូវសំពាធខាងក្នុងប្រទេសដោយមានការធ្វើបាតុកម្មតវ៉ាជាច្រើន និងមានអំពើហិង្សានៅតាមទីក្រុងធំៗ របស់ប្រទេស។

នាខែមិថុនា ឆ្នាំ១៩៩៨ ប្រធានាធិបតីថ្មីហាប៊ីប៊ី ដែលចង់បានជំនួយអន្តរជាតិដើម្បីជួសជុលការខូចខាតដែលបណ្តាលមកពីវិបត្តិសេដ្ឋកិច្ច បាននិយាយថា ត្រៀមខ្លួនដើម្បីយល់ព្រមឱ្យទីម័រខាងកើត នូវលក្ខខណ្ឌតិកៈពិសេស។ នៅថ្ងៃ៥ ខែឧសភាបន្ទាប់ក្រោមការការពារពីអង្គការសហប្រជាជាតិឥណ្ឌូនេស៊ី និងព័រទុយហ្គាលក៏បានចុះហត្ថលេខា លើកិច្ចព្រមព្រៀងដែលគ្រោងទុកការបោះឆ្នោតប្រជាមតិនៅថ្ងៃទី៣០ សីហា ឆ្នាំ១៩៩៩។

លុះមកដល់ថៃកំណត់ ៣០ ខែសីហា ឆ្នាំ១៩៩៩ ជនជាតិទីម័រ បានជ្រើសរើសឯករាជ្យភាព នៅក្នុងការបោះឆ្នោតប្រជាមតិដែលរៀបចំធ្វើឡើងដោយអង្គការសហប្រជាជាតិ។

**ឯករាជ្យភាព**

នាខែមេសា ឆ្នាំ២០០១ ជាការបោះឆ្នោតលើកទីមួយរបស់ប្រទេស។ លោក សាណាណា ហ្គូស្មាវ ត្រូវបានបោះឆ្នោតជ្រើសរើស និងកាន់អំណាច ជាប្រធាធិបតីរបស់ប្រទេសថ្មីនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០២ ដែលនេះកត់សម្គាល់នូវព្រឹត្តិការណ៍ឯករាជ្យភាពពិតប្រាកដនៃទីម័រខាងកើត។



Photos : DR

MesOctober-2010 OK.qxd 10/4/2010 4:47 PM Page 17





Photo : Ngean Lida

# បំបួសទន្លេ និងដើមឈើ ជាពិធីតាមបែបពុទ្ធសាសនាការពារធម្មជាតិ

**ខាន់ ភីរម្យ**

ព្រះភិក្ខុ យឹម សុភា គង់នៅវត្តព្សសានរតនារាម ទីក្រុងបានលុង ខេត្តរតនគិរី បានបានមានព្រះសង្ឃដីកាថា ការបំបួសទន្លេឬដើមឈើ ជាពិធីមួយតាមបែបពុទ្ធសាសនាដើម្បីការពារធនធានធម្មជាតិ ឬអ្វីៗ ដែលព្រះសង្ឃបានបំបួសនោះ។

ព្រះអង្គបានមានព្រះសង្ឃដីកា បញ្ជាក់ទៀតថា អត្ថន័យរបស់ពិធីបំបួសទាំងនេះគឺជំរុញឱ្យមនុស្សចេះការពារ ថែរក្សា និងសម្ដែងការគោរពដឹងគុណចំពោះធម្មជាតិ-បរិស្ថាន ដែលបានផ្ដល់ភោគផលផ្សេងៗដើម្បីឱ្យមនុស្សយើង យកវាមកប្រើប្រាស់ដោះស្រាយជីវភាពក្នុងការរស់នៅ ប្រកបដោយសមធម៌។

ព្រះអង្គបានបន្តទៀតថា ពិធីបំបួសនេះគឺគេមិនមែនអាចធ្វើបានតែចំពោះទន្លេ ឬដើមឈើតែប៉ុណ្ណឹងនោះទេ។ គ្រប់អ្វីៗ ក្នុងធម្មជាតិ ដែលមនុស្សគិតថា មានប្រយោជន៍ គឺព្រះសង្ឃ អាចនឹងធ្វើការបំបួសបានទាំងអស់ ដោយរួមទាំង បំបួសខ្សាច់ ភ្នំ ឬថ្ម និងអ្វីៗជាច្រើនទៀត។

តាមព្រះសង្ឃដីកា ព្រះភិក្ខុ យឹម សុភា ពិធីបំបួលនេះ គេអាចនឹងធ្វើឡើងនោះ គឺមិនមានការស្មុគស្មាញអ្វីច្រើននោះទេ។

ព្រះអង្គបានមានសង្ឃដីកាបញ្ជាក់ឱ្យដឹងថា : "ឧទាហរណ៍ បើញាតិញោមណាចង់ធ្វើការបំបួសដើមឈើណាមួយ ដែលគាត់អាចគិតថា មានប្រយោជន៍ដល់សង្គម គឺគេគ្រាន់តែរៀបចំការពារថែរក្សា ហើយយកជីទៃក្រហមទៅចង នៅលើដើមឈើនោះដោយនិមន្តព្រះសង្ឃទៅធ្វើពិធីបំបួស ហើយគេទាំងអស់នាំគ្នាការពារ និងថែរក្សាទៅជាការស្រេច"។

តាមសង្ឃដីកាបន្តរបស់ ព្រះភិក្ខុ សុភា កាលណាវត្ថុ ឬជាអ្វីមួយត្រូវបានបំបួសរួចរាល់ហើយនោះ បើប្រសិនជនណាម្នាក់យករបស់កខ្វក់ទៅដាក់ ប៉ះពាល់នឹងវត្ថុ ឬក៏ធ្វើសកម្មភាពណា ដែលអាចបង្កផលអន្តរាយទៅដល់វត្ថុបំបួសនោះ គេមានជំនឿថាអ្នកនោះនឹងត្រូវមានកម្មពៀរវេរា ថ្ងៃក្រោយជាក់ជាមិនខានឡើយ។

ព្រះអង្គបានបន្តទៀតថា ទោះជាយ៉ាងណា បើក្នុងករណីដែលសហគមន៍គិតថាគេចង់ប៉ះពាល់វត្ថុដែលបំបួសនោះវិញ ដោយសារតែមានហេតុផលណាមួយផ្សេងៗ គេអាចនឹងធ្វើបាន លុះត្រាតែសហគមន៍នោះនិមន្តព្រះសង្ឃទៅផ្សឹកវត្ថុបំបួសនោះ ជាមុនសិន ទើបគេអាចនឹងធ្វើអ្វីបានទៅតាមការសម្រេចរបស់សហគមន៍។

អំណាន

## រឿងគ្មានចេកញុាំទេ



នៅថ្ងៃនេះ កូនស្វា ពិតជាឃ្លានខ្លាំងណាស់។ គេទៅរកចេកពីម្ដាយរបស់គេនៅផ្ទះ តែមិនមានចេកស៊ីទេ។ គេទៅរកចេកនៅផ្ទះបងក្មេកតែគ្មាន។ គេក៏ទៅរកចេកនៅផ្សារតែនៅតែគ្មានដែរ។ កូនស្វាក៏ទៅរកនៅលើទូកក្រោមទឹកនៅផ្ទះមិត្តភក្តិ... នៅតែគ្មាន។ វាកើតទុក្ខខ្លាំងណាស់។

តែស្អែកឡើង ទូកដឹកចេកបានមកដល់។ អ្នកដែលកូនស្វាទៅសុំចេកកាលពីម្សិលមិុញ ត្រឡប់មករកគេវិញ ជាមួយនិងចេកគ្រប់ៗដៃ។ តែកូនស្វាឃ្លានដូងវិញម្ដង !

នេះគឺជារឿងបែបប្រដេញយ៉ាងពីរោះសម្រាប់អានឱ្យកុមារតូចៗ អាយុឆ្នាំឡើងទៅស្ដាប់កំសាន្ត។ ពួកគេក៏នឹងសប្បាយជាមួយអ្នកដោយរៀននិយាយនូវឃ្លាដដែលៗ។ ហើយតាមរយៈរឿងនេះ អ្នកអាចបង្កើតបានរឿងថ្មីៗជាច្រើន ដោយគ្រាន់តែដូរវត្ថុដែលកូនស្វាចង់ស៊ី !

សៀវភៅរឿងនេះ គឺមានកម្រាស់៣២ទំព័រ និងនិពន្ធដោយសាសា អាលីសាន់ និងគូររូប ដោយអូនឡា សានទី (ជនជាតិឡាវ) ដោយប្រែជាភាសាខ្មែរ ដោយ សុទ្ធ បូផា និងបោះពុម្ពនៅឆ្នាំ២០១០។

## រឿងនាង សមាភារី



ប្រទេសកម្ពុជានាឆ្នាំ១៨៧៤ ស្ថិតនៅក្នុងរជ្ជកាល ព្រះបាទនរោត្តម...។ ចាប់តាំងពីឪពុកស្លាប់ទៅ សមាភារីរស់នៅតែពីរនាក់ ជាមួយម្ដាយនៅក្នុងផ្ទះដ៏ស្ងប់ស្ងាត់ ប្រកបដោយជីវភាពស្ដុកស្ដម្ភមួយ។ តែសន្តិភាពនេះមិនបានយូរអង្វែងទេ ព្រោះអ្នកស្រីណម ណាម ជាម្ដាយ ជួបប្រុសរូបល្អម្នាក់ឈ្មោះ នាយស្រគាំ។ ជនពាលម្នាក់នេះចិញ្ចឹមចិត្តបោកយកប្រាក់ស្ត្រីមេម៉ាយ និងយកកូនក្រមុំគាត់។

ថ្ងៃមួយវេលាដែលជម្លោះរវាងនាយស្រគាំ និងសមាភារីឡើងដល់កម្រិតកំពូល អ្នកស្រីណមណាម បានជ្រើសរើសយកប្ដីថ្មី និងបណ្ដេញកូនស្រីចេញពីផ្ទះ។ សមាភារីក៏ត្រូវចេញដំណើរឆ្លងកាត់ឧបសគ្គសព្វបែបយ៉ាង គឺជួបទាំងមនុស្សឃោរឃៅ ទាំងមនុស្សល្អ ជួបក្ដីស្នេហា ការព្រាត់ប្រាសសុភមង្គល និងទុក្ខសោក...។

សមាភារី គឺជាស្នាដៃប្រលោមលោកមួយរបស់លោក រីម គិន។ តាមរយៈស្នាដៃនេះ យើងអាចស្គាល់ពីសំណេរ ឬវាក្យសព្ទ កាលពីសម័យមុន និងអាចបណ្ដែតអារម្មណ៍ទៅកាន់ជីវិតប្រជាជនខ្មែរនាសតវត្សរ៍ទី១៩។

**ហួត សុជាតា**

MesOctober-2010 OK.qxd 10/4/2010 4:47 PM Page 18

# អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ



## ខែតុលា ដោយលោកគ្រូដួង សាខន់

**អាទិត្យទី២៨ រដូវធម្មតា (ថ្ងៃទី១០ តុលា ឆ្នាំ២០១០)** *(លូកា ១៧:១១-១៩)*

ថ្ងៃនេះ ព្រះយេស៊ូប្រោសមនុស្សឃ្លង់ ១០នាក់ ឱ្យជាសះស្បើយ ។ ព្រះយេស៊ូប្រោស ដោយគ្រាន់តែឱ្យគេទៅបង្ហាញខ្លួនដល់បូជាចារ្យប៉ុណ្ណោះ ។ តាមគម្ពីរ អ្នកឃ្លង់ជានិមិត្តរូបមនុស្សយើង ដែលមានបាបឃ្លាតឆ្ងាយពីព្រះបិតា ។

អតីតអ្នកឃ្លង់ម្នាក់វិលមកថ្វាយបង្គំព្រះយេស៊ូវិញដើម្បីអរព្រះគុណព្រះអង្គមានន័យថាគាត់ទទួលព្រះយេស៊ូទុកជាមហាបូជាចារ្យ ។ ទតឃើញដូច្នេះព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា : "អញ្ជើញទៅចុះ ជំនឿរបស់អ្នក "សង្គ្រោះ" អ្នកហើយ" ។ គួរកត់សម្គាល់ថា ព្រះយេស៊ូមិនមានព្រះបន្ទូលថា ជំនឿរបស់អ្នកព្យាបាលឱ្យអ្នក "ជាស្អាត" ទេ តែមានបន្ទូលថា ជំនឿរបស់អ្នក "សង្គ្រោះ" អ្នកហើយ ។ ពាក្យ "សង្គ្រោះ" មានន័យថា ព្រះអង្គប្រោសគាត់ឱ្យអាចទាក់ទងនឹងព្រះបិតាបាន ។

អត្ថបទថ្ងៃនេះព្រះសហគមន៍សូមឱ្យយើងចាប់អារម្មណ៍អំពីឋានៈរបស់ព្រះយេស៊ូ គឺព្រះអង្គជាព្រះសង្គ្រោះដែលណែនាំមនុស្សលោកឱ្យអាចទាក់ទងនឹងព្រះបិតា ។ **តើព្រះយេស៊ូជាព្រះសង្គ្រោះខ្ញុំយ៉ាងណា ?**

**អាទិត្យទី២៩ រដូវធម្មតា (ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១០)** *(លូកា ១៨:១-៨)*

អត្ថបទប៉ុន្មានអាទិត្យមុន ព្រះយេស៊ូសូមឱ្យសាវ័កមានជំនឿ ហើយថ្ងៃនេះព្រះអង្គសុំឱ្យសាវ័កខិតខំអធិដ្ឋានជានិច្ចកុំរសាយចិត្តឡើយ នេះមានន័យថា ជំនឿត្រូវតែជាប់ជាមួយការអធិដ្ឋាន ។ ព្រះយេស៊ូមានព្រះបន្ទូលជាប្រស្នាថា មានចៅក្រមម្នាក់ គាត់មិនអាចពន្យាពេលកាត់ក្តីឱ្យស្ត្រីមេម៉ាយម្នាក់បានទេ ព្រោះស្ត្រីនេះចេះតែរំខានគាត់គ្រប់ពេលអង្វរឱ្យគាត់ឆាប់រកយុត្តិធម៌ឱ្យ ។ បន្ទាប់មកព្រះយេស៊ូមាន ព្រះបន្ទូលលើកទឹកចិត្តសាវ័កថា ព្រះជាម្ចាស់ព្រះអង្គកាន់តែស្តាប់ពាក្យអង្វរ និងរកយុត្តិធម៌ឱ្យអ្នកដែលចេះតែអធិដ្ឋាទៅរកព្រះអង្គលើសចៅក្រមនោះទៅទៀត ។

ថ្ងៃនេះព្រះយេស៊ូ សូមឱ្យយើងយកចិត្តទុកដាក់អធិដ្ឋានទាក់ទងនឹងព្រះបិតាដោយជំនឿ និងដោយអស់ពីចិត្ត និងដោយស្និទ្ធស្នាលដែរ កុំរសាយចិត្ត ឬកុំអស់សង្ឃឹមនៅពេលដែលព្រះអង្គមិនទាន់ឆ្លើយតបមកយើងភ្លាមៗ ។ **តើខ្ញុំមានបទពិសោធន៍យ៉ាងណាដែរក្នុងការអធិដ្ឋាន ?**

**អាទិត្យទី៣០ រដូវធម្មតា (ថៃទី២៤ ខែតុលា ឆ្នាំ២០១០)** *(លូកា ១៨:៩-១៤)*

អត្ថបទនេះព្រះយេស៊ូប្រៀនប្រដៅដល់អស់អ្នកដែលស្មានថា ខ្លួនបានសុចរិតដោយខ្លួនឯង ហើយមើលងាយអ្នកដទៃ ដោយលើកប្រស្នាអំពីអ្នកទារពន្ធ និងបុរសខាងគណៈផារីស៊ីអធិដ្ឋានក្នុងព្រះវិហារមកពន្យល់ ។

ពេលអធិដ្ឋានបុរសខាងគណៈផារីស៊ីមិនសុំអ្វីសោះពីព្រះជាម្ចាស់ តែគាត់ខំពន្យល់ព្រះអង្គអំពីរបៀបដែលគាត់រស់នៅល្អជាងអ្នកឯទៀត ដែលសុទ្ធតែជាចោរ ឬផិតក្បត់... ។ គាត់តមអាហារពីរដងក្នុងមួយអាទិត្យ ។ គាត់យល់ថា ខ្លួនបានសុចរិតដោយសារកិច្ចការទាំងនោះ ។ ផ្ទុយពីគាត់ អ្នកទារពន្ធម្នាក់ គាត់បន្ទាបខ្លួនយ៉ាងខ្លាំងក្នុងពេលអធិដ្ឋាន គាត់ទទួលខ្លួនថា ជាអ្នកបាប គ្មានបុណ្យកុសល ហើយគាត់អង្វរសូមព្រះជាម្ចាស់លើកលែងទោសឱ្យគាត់ ។ ព្រះយេស៊ូមានព្រះបន្ទូលថា អ្នកទារពន្ធនោះត្រឡប់ទៅជា មនុស្សសុចរិតវិញ ដ្បិតគាត់ផ្ញើជីវិតទាំងស្រុងលើព្រះជាម្ចាស់ គាត់ប្លែកពីបុរសខាងគណៈផារីរី ដែលពឹងផ្អែកលើបុណ្យកុសលរបស់ខ្លួន ។ **តើខ្ញុំដូចនរណាក្នុងអត្ថបទនេះ ?**

**អាទិត្យទី៣១ រដូវធម្មតា (ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១០)** *(លូកា ១៩:១-១០)*

តាមវប្បធម៌យូដា អ្នកទារពន្ធ គឺជាអ្នកបាបដែលសង្គមស្អប់ខ្ពើម ។ លោកសាខេជាអ្នកទារពន្ធ គាត់ចង់ឃើញព្រះយេស៊ូមានភិនភាគយ៉ាងណា ។ ដោយសារគាត់មាឌតូច ហើយមានមនុស្សជាច្រើនព័ទ្ធជុំវិញព្រះយេស៊ូ ហេតុនោះគាត់ក៏ខំឡើងលើដើមឈើដើម្បីឃើញព្រះអង្គ ។ ពេលយាងមកដល់ ព្រះយេស៊ូអញ្ជើញគាត់ឱ្យចុះមក ហើយព្រះអង្គយាងទៅស្នាក់នៅផ្ទះគាត់ ដែលមនុស្សខ្លះចោទថា ព្រះអង្គប្រព្រឹត្តខុសវិន័យ ។ លោកសាខេ ប្រែចិត្តទូលទៅព្រះយេស៊ូថា គាត់នឹងចែកទ្រព្យសម្បត្តិពាក់កណ្តាល ដល់អ្នកក្រីក្រ និងសងមួយជាបួនដល់អ្នកដែលគាត់ទារពន្ធលើស ។

អត្ថបទនេះប្រាប់យើងថា ព្រះយេស៊ូយាងមកដើម្បីរកអ្នកបាបឱ្យប្រែចិត្ត ហើយអ្នកបាបដែលប្រែចិត្តក៏ត្រូវតែធ្វើកាយវិការណាមួយសម្តែងពីការសោកស្តាយរបស់ខ្លួនដែរ ។ **តើខ្ញុំដូចលោកសាខេយ៉ាងណា ?**

---

**កំណាព្យ**

### ព្រាសាទព្រះវិហារជារបស់ខ្មែរ

១-ខ្មែរធ្លាប់មានឈ្មោះពិរោះល្បី នៅលើលោកីយ៍ល្បីចំណាន
ឆើតឆាយសព្វគ្រប់ទីស្ថាន ឥឡូវមិនសូវស្រាន្តព្រោះវឹកវរ ។
២-ឱ ! ព្រះវិហារនាកាលដើម ល្អល្អះច្បាស់ឆើមឆើ្យមនគរ
ក្បាច់ក្បូរត្រដែតហេតុបវរ ចម្លាក់កិន្នរល្អប្រិមប្រិយ ។
៣-វិហារជាប្រាង្គរបស់ខ្មែរ ដែលឋិតនៅក្បែរទល់ដែនថៃ
កេរពីដូនតាយូរលង់ក្រៃ នៅលើទឹកដីកម្ពុជា ។
៤-ពេលនេះរងគ្រោះព្រោះតែជន មានចិត្តលោភលន់ធ្ងន់ដូចមារ
ប្រាថ្នាហួងហែងស្វែងទាមទារ ប្រាង្គព្រះវិហារជារបស់គេ ។
៥-កោតតែថ្លាថ្លៃងមិនក្រែងចិត្ត ចង់បានមិនគិតពីតំណរ
សិលាចារិកនឹកស្ថិតស្ថេរ នាមក្សត្រខ្មែរទេអ្នកកសាង ។
៦-ព្រះបាទយសោវរ្ម័នក្សត្រ ព្រះនាមមិនខ្វាត់នៅជាតាង
ហេតុម្តេចបានជាអ្នកសំអាង អ្វីៗ គ្រប់យ៉ាងរបស់ខ្លួន ។
៧-នៅតែមានៈមិនឃ្លាតឃ្លា ស្ម័គ្រកាយគ្រប់គ្រាចង់ថៃធួន
តស៊ូព្យាយាមមិនដេកពួន ព្រោះគិតថាខ្លួនឯងជាម្ចាស់ ។
៨-មិនគួរមិនគិតរឹតខំប្រឹង តស៊ូដល់ម្លឹងបានអ្វីខ្លះ?
ទើបបានចង់ចាញ់ចង់ឈ្នះណាស់ ម្តេចមិនក្រឡាស់ត្រឡប់ក្រោយ ។
៩-កូនខ្មែរឈាមខ្មែរស្នេហាជាតិ ជនដែលមានស្មៀតមិនបណ្តោយ
ឱ្យលេបទឹកដីសេរីឡើយ ឈាមខ្មែរនេះហើយអ្នកតស៊ូ ។
១០-រួបរួមកម្លាំងខ្លាំងសាមគ្គី ទោះអស់ជីវីក៏ហ៊ានប្តូរ
ខាំមាត់សង្កត់អត់មិនថ្ងូរ ត្រូវគិតមុនគួរទើបប្រពៃ ។

**និពន្ធដោយអ្នកស្រីខុង ណារី**

# ភាពយន្តសក្ខីភាពអ្នកម្តាយតេរេសា និងការប្រជុំអង្គការស៊ីដនីសអាស៊ី

## ការិយាល័យព័តមានកាតូលិក

*ក្នុងអំឡុងខែកញ្ញាកន្លងទៅ សមាជិកការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិកបានរៀបចំមហោស្រពភាពយន្តអ្នកម្តាយតេរេសា និងទៅកាន់ស៊ីដនីអាស៊ី ។*



លោកគីកេថ្លែងមតិក្នុងមហោស្រពភាពយន្តអ្នកម្តាយតេរេសា



ក្រុមយុវជនស្ម័គ្រចិត្ត បុគ្គលិកស៊ីអេសស៊ី និងលោកអភិបាលគីកេ ថតរួមគ្នាជាអនុស្សាវរីយ៍ក្នុងថ្ងៃសម្ពោធខ្សែភាពយន្ត




មហាសន្និបាតស៊ីដនីសអាស៊ីដែលរៀបចំធ្វើនៅប្រទេសឥណ្ឌូនេស៊ីឆ្នាំនេះមានគណៈប្រតិភូ ១៩ប្រទេស ចូលរួម




សមាជិកគណៈកម្មការនាយកស៊ីដនីសអាស៊ីថតរូបរួមគ្នានៅពិធីបិទសន្និបាតស៊ីដនីសអាស៊ី ធ្វើពីថ្ងៃ២០-២៥ កញ្ញា នៅស៊ូរ៉ាបាយ៉ា ឥណ្ឌូនេស៊ី




លោកអូហ្គូស្ទីន ឡូអូធូសាមី ប្រធានស៊ីនីស ពិភពលោក ប្រគល់រង្វាន់មេឌាលេខមួយ ទៅប្រទេសឥណ្ឌូនេស៊ី លើវីដេអូមួយនាទីស្តីអំពីបរិស្ថាន



គណៈប្រតិភូស៊ីដនីសអាស៊ីធ្វើដំណើរទស្សនកិច្ចសិក្សានៅ SBO ធីវី នៃ ស៊ូរ៉ាបាយ៉ា ក្នុងអំឡុងពេលសន្និបាទ

## វិទ្យុវេរីតាស់អាស៊ី (RVA) ផ្នែកភាសាខ្មែរផ្សាយរយៈពេល ៥៧នាទី ជារៀងរាល់ថ្ងៃតាមរយៈ រលកធាតុអាកាសខ្លី (Short Wave = sw) គឺ :

~ពេលព្រឹក ពីម៉ោង ៨:៣០នាទី ដល់ម៉ោង ៨:៥៧នាទី ផ្សាយក្នុងរលកធាតុអាកាស ១៥២៨០ គីឡូហឺតស៍ ត្រូវនឹងកម្ពស់ ១៩,៦៣ ម៉ែត្រ។

~ពេលព្រឹក ពីម៉ោង ៥:០០នាទី ដល់ម៉ោង ៥:៣០នាទី ផ្សាយក្នុងរលកធាតុអាកាស ១១៨៥០ គីឡូហឺតស៍ ត្រូវនឹងកម្ពស់ ២៥,៣២ ម៉ែត្រ។

ស្តាប់វិទ្យុវេរីតាស់ អាស៊ី (RVA)លោកអ្នកនឹងទទួលបានចំណេះដឹង អំពីជីវិត និងសង្គម និងព័ត៌មាននានាពីព្រះ សហគមន៍កាតូលិកនៅកម្ពុជា។

## ល្បែងកំសាន្ត

**ផាត់ពណ៌**

សូមប្រិយមិត្តផាត់ពណ៌ឱ្យកូនដំរីដ៏គួរឱ្យស្រឡាញ់នេះផង។



Photo : jeux-loisirs-enfants

## ការងារប្រចាំខែ

- ថ្ងៃទី២៩ កញ្ញា ដល់ថ្ងៃទី២ តុលា : មហាសន្និបាតយុវជន ក្រោមប្រធានបទ (ខ្ញុំជាសាក្សីរបស់ព្រះយេស៊ូគ្រីស្តក្នុងសង្គម) មានយុវជនប្រមាណ ៨០នាក់ នៅមណ្ឌលសកម្មភាពព្រះសហគមន៍កំពង់សោម។
- ថ្ងៃទី១ តុលា : មានពិធីអធិដ្ឋានផ្តាំតាមផ្ទះសម្រាប់គ្រីស្តបរិស័ទនៅក្រុងព្រះសីហនុ។
- ថ្ងៃទី៥-៩ តុលា : គ្រូអប់រំជំនឿអូស្ត្រាលី ៥នាក់ មកស្វែងយល់អំពីព្រះសហគមន៍នៅកម្ពុជា និងផ្លាស់ប្តូរបទពិសោធន៍នៅព្រះវិហារកំពត ជុំគីរី និងកោះស្លា។
- ថ្ងៃទី៧-៩ តុលា : ពិធីបុណ្យភ្ជុំបិណ្ឌ និងពូនភ្នំខ្សាច់ នៅក្នុងព្រះវិហារសៀមរាប។
- ថ្ងៃ៨ ខែតុលា : យុវជន៦នាក់ ទទួលជំហានទី១នៅព្រះវិហារបេះដូងព្រះយេស៊ូ ខេត្តប៉ៃលិន។
- ថ្ងៃទី១០ តុលា : ទិវាព្រះគម្ពីរ ឆ្នាំ២០១០ នៅព្រះវិហារសន្តយ៉ូសែប ទីក្រុងភ្នំពេញ។
- ថ្ងៃ១០ ខែតុលា : ពិធីទទួលស្វាគមន៍លោកបូជាចារ្យវណ្ណាថៃយ៉ាន អរគ្គី យ៉ាដុស្សជាបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍កាតូលិកចំការទៀង ខេត្តតាកែវ។
- ថ្ងៃទី១៣ តុលា : ទិវាសុខភាពភ្នែកពិភពលោក នៅមន្ទីរពេទ្យភ្នែកតាកែវ។
- ថ្ងៃទី១៦-១៨ តុលា : យុវជនសិង្ហបុរី ៦នាក់ មកពីព្រះវិហារ Saint Francis Savier Chruch ស្ម័គ្រចិត្តបង្រៀនភាសាអង់គ្លេសដល់យុវជន និងស្វែងយល់អំពីព្រះសហគមន៍កំពត។
- ថ្ងៃ១៧ ខែតុលា : ពិធីទទួលស្វាគមន៍លោកបូជាចារ្យប្រ៊ុយណូ កូសម៉ីជាបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍កាតូលិកសន្តយ៉ូសែប ហៅផ្សារតូច នៅរាជធានីភ្នំពេញ។
- ថ្ងៃ២៧ ខែតុលា : ពិធីទទួលស្វាគមន៍លោកបូជាចារ្យប៉ប ពិសេ ជានាយកទេវវិទ្យាល័យសន្តយ៉ូហាន ម៉ារី វីយ៉ាណេ នៅកម្ពុជា។
- ថ្ងៃទី២៨ ខែតុលា : ពិធីសម្ពោធវត្តអារាមរបស់ក្រុមដូនជីសម្ងាត់។

**ការិយាល័យរចនា និងវប្បធម៌**

(ភូមិភាគបាត់ដំបង) មានទទួលប៉ាក់សម្លៀកបំពាក់គ្រប់ប្រភេទក្នុងតម្លៃសមរម្យ។
ទំនាក់ទំនងកញ្ញាសួន ប៊ុណ្ណារេត លេខទូរស័ព្ទ : ០១៧ ៣៤ ២៨ ៣៤។ សូមអរគុណ !
Emai : sounbunareth@yahoo.com